# សៀវភៅគតិលោក
# ភាគ ទី៦



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

ChanBoKeo.com

# រឿងសត្វកង្កែបនិងគោ

មានសត្វកង្កែប១ នៅក្នុងស្រះថ្ងៃមួយមានគោ១ ចុះទៅផឹកទឹកស្រះនោះ កង្កែបឃើញហើយក៏នឹកក្នុងចិត្តថា អាសត្វគោនេះម្ដេចរូបវាធំម្ល៉េះ បើដូច្នេះអញនឹងបំពើតកាយបំប៉ោងខ្លួនឡើងឲ្យធំដូចគោនេះបានអេះ កង្កែបគិតដូច្នោះហើយតាំងបំប៉ោងកាយ ចំអើតជើងឡើង ហើយហៅទៅកាន់គោនោះថា "នែប្រស្ដែងគោចូលមើលមករូបយើងឯងណេះយើងធំប៉ុនប្រស្ដែងឯងហើយឬ?។

ឯគោក៏តបថា "នៅទេចៅកង្កែបចូរខំបំពើតបំប៉ោងឡើងបន្តិចទៀត"។ កង្កែបឮដូច្នោះ ក៏ខំប្រឹងកាងចំកោងបំពើតប៉ោងឡើងលើសមុន ហើយក៏ហៅទៅគោថា "ម៉េចម្ដងណេះ ប្រស្ដែងគោរូបយើងធំប៉ុនអ្នកឯងហើយឬៗនៅទាស់ត្រង់ណាទៀត?។

ឯគោក៏តបថា "នៅទេកង្កែបចូរខំប្រឹងបំប៉ោងឡើយទៀតទៅ"។ កង្កែបក៏ខំប្រឹងខាំមាត់តាំងកាងចំកោងបំប៉ោងពេញកំលាំង ខ្យល់អស្សាសបស្សាសដង្ហើមចូលចេញមិនបានកាយកង្កែបនោះក៏បែកធ្លាយ ចេញពោះវៀនលៀនលេចមក



ខាងក្រៅដល់នូវមរណកាលក្នុងកាលនោះហោង។

រឿងនេះ បានគតិអ្នកតូចចង់ជាធំគឺចង់ត្រាប់កាយអ្នកធំពុំសមក្ដីប្រាថ្នា ក៏វិនាសអាត្មាឯងវិញ។ មួយទៀត បានគតិដូចបុរាណតែងថា "ដំរីជុះៗតាមដំរី" នោះឯង មួយទៀតមានបទបាលីក្នុងគម្ពីរលោកនីតិថា៖

អប្បរូបោ ពហុភាសោ
អប្បបញ្ញោ បកាសិតោ
អប្បបុរោ ឃដេ ខោភេ
អប្បខីរា តាវី ចលេ។

ប្រែថា ជាតិអ្នកទាបភាពតូចសំដីខ្ពស់ ឥតប្រាជ្ញក្លាយសប្រកាសថ្លែង ពាងក្អមទឹកមិនពេញក្រឡុកគ្រលែង មេគោឯងទឹកដោះតិចតេបធាក់ក្រាន។

មួយទៀតថា៖

អជនស្ស រសំ ខាជា
អពលស្ស ហតា នរា
អប្បញ្ញស្ស វាក្យា កថា
ឧម្មត្តកសមា ឥមេ។

ប្រែថា អ្នកឥតធនធាន ចង់ទទួលទាន រសឆ្ងាញ់លើសលែង អ្នកឥតកម្លាំង ចង់តាំងសំដែង ចំបាប់ទាត់ប៉ែង សំដែងអំនួត ៗ អ្នកឥតប្រាជ្ញា ល្មោភថ្លែងចរចា ប្រាថ្នាគេអួត ជន៣នេះប្រើ ទុកស្មើមនុស្សឆ្កួត ព្រោះឡើងអំនួត ល្មោភហួសប្រមាណ ៗ

**ចប់តម្រាតូចចង់ធ្វើធំទី ២៣។**

## រឿងលាឈ្មោល ១ ត្រាប់តាមកូនឆ្កែ

**និទាននេះមានដំណាលក្នុងក្បួនបារាំងសែស**

មានសត្វលាឈ្មោល ១ ជាសត្វចិញ្ចឹមជាពាហនៈរបស់សេដ្ឋី លានោះបានឃើញសេដ្ឋីជានាយស្រឡាញ់ ឱបរឹតប្រឡែងលេង នឹងកូនឆ្កែជាប្រក្រតី ទើបគិតថា អាកូនឆ្កែនេះវាចេះធ្វើលើសអញ បានជានាយគាត់ស្រឡាញ់ឱបរឹត ស្និទ្ធស្នាលនឹងវាដល់ម្ល៉េះ បើដូច្នេះអញចាំមើលលោកនាយបើគាត់មកជិតអញកាលណាអញនឹងលោទៅឱបគាត់ ឲ្យគាត់ឱបរឹតអញប្រឡែងលេងឲ្យដូចជាអាកូនឆ្កែនោះខ្លះ គិតហើយលារង់ចាំមើលសេដ្ឋី លុះសេដ្ឋីដើរមកជិតខ្លួនបានឱកាសហើយ ក៏លោជើងទាំងពីរទៅនឹងឱបសេដ្ឋីជានាយ ៗ

ឯសេដ្ឋីឃើញលាចំប្រាវមកដូច្នោះ គិតថាលាលោមកនឹងធាក់



ប្រំអាត្មា ទើបខឹងលាក៏ចាប់ដំបងវាយសំពងលានោះ ៥-៦ដំបង ហើយជេរខ្មោចអាលាចង្រៃ កាចខូចអ្វីម្ល៉េះវាហ៊ានគិតនឹងធាក់ប្រំខាំឯងជាម្តង ឯលានោះត្រូវដំណំ ៥-៦ ដំបងដល់នូវក្តីទុក្ខវេទនា កើតទោមនស្ស តូចចិត្តអាណិតខ្លួនព្រោះពុំសមក្តីប្រាថ្នាឲ្យដូចជាកូនឆ្កែនោះឯង ៗ

រឿងនេះ បានគតិដូចបុគ្គលឃើញនាយចៅហ្វាយឬអ្នកធំលោកមានចិត្តស្ម័គ្រលេងលចំអកចំអន់នឹងអ្នកឯណាមួយ ហើយខ្លួនឯងលោកមិនដែលលេងលសោះឡើង ហើយទៅនិយាយឬប្រើអាការស្និទ្ធដូចជាបុគ្គលដែលលោកធ្លាប់លេងនោះប្រព្រឹត្តទៅមិនបានដូចគេទេ តែប្រព្រឹត្តហើយគង់ដល់ក្តីបរាមុខនាកណ្តាលជំនុំប្រជុំជន ដូចយ៉ាងលាចង់ត្រាប់កូចឆ្កែនេះឯង គួរចូលចិត្តហោងៗ មួយទៀត ចុះគតិថា "គេមិនលេង ខ្លួនទៅលេង គេមិនសួរ ខ្លួនទៅថ្លែង" ការអស់នេះ បានក្តីហីនលក្ខណៈក្នុងលោកយនេះប្រាកដ ដូចបទបាលីក្នុងគម្ពីរលោកនីតិថា៖

**អនវ្ហយំ តមយន្តោ អបុច្ឆា ពហុភាសកោ**

**អត្តកុណំ បកាសេន្តោ តិវិធំ ហីនលក្ខណំ។**

ប្រែថា គេមិនហៅចូលទៅ ទៅមិនគួរ គេមិនសួរឆ្លើយឯង

លើសប្រមាណ ប្រកាសគុណនៃកាយដែលពុំមាន បីនេះបាប ឈ្មោះហៅហីនល័ក្ខណ៍ ៗ

## ចប់តម្រាគតិធំគ្រាប់តូចខូចខ្លួនទី ២៤។

# រឿងចៅគង្វាលពពែម្នាក់

មានចៅគង្វាលពពែម្នាក់គៀងពពែទៅឲ្យស៊ីស្មៅនៅព្រៃក្រៅ១ នាំសុនខស្រុក១ ទៅផងលុះទៅដល់ដើមឈើធំ១ មានម្លប់ត្រជាក់សប្បាយ ចៅគង្វាលពពែក៏ដោះអាវដោះមួក ដាក់ពាក់ទៅលើមែកឈើ ដាក់ឈើច្រត់ផ្អែកទៅលើប្រគាបឈើ ១ ហើយដេកលេងរំហើយខ្យល់ ឯឆ្កែស្រុកនោះ ក៏ដេកនៅខាងខ្លួន លុះត្រូវខ្យល់ត្រជាក់ ចៅនោះក៏ដេកលក់ ទាំងឆ្កែក៏ដេកលក់នៅក្រោមដើមឈើនោះឯង ៗ

កាលនោះមានឆ្កែព្រៃ១ ដើរមក ឃើញហ្វូងពពែច្រើនគិតចង់ចាប់ស៊ី តែចូលទៅជិតហ្វូងពពែកាលណា ពួកពពែទាំងឡាយភិតភ័យផ្អើល នាំគ្នាបោលចូលទៅកាន់សំណាក់ឆ្កែស្រុក នឹងម្ចាស់វាអស់ទៅ ឆ្កែព្រៃរកឱកាសនឹងចាប់ពពែនោះពុំបាន ៗ ថ្ងៃមួយ ឆ្កែព្រៃគិតថា អាពួកពពែអស់នេះតែវាឃើញរូបអញកាលណា វាសឹងផ្អើលបោលទៅរកម្ចាស់វា ឲ្យជួយតែរាល់



ដង ឯត្រង់ម្ចាស់វាដើរមកជិតម្ដេចក៏វាមិនផ្អើល បើដូច្នេះចាំអញទៅលួចយកអាវមួកនឹងឈើច្រត់ មកស្លៀកពាក់ត្រាប់ឲ្យដូចម្ចាស់វាទើបវាមិនផ្អើល ជាឱកាសងាយចាប់ស៊ីបាន ឆ្កែព្រៃគិតដូច្នោះហើយ ទើបដើរអមវាំងចូលទៅមើលអាការនាយគង្វាលនោះ លុះឃើញនាយគង្វាលនឹងឆ្កែស្រុកដេកលក់ ក៏ចូលទៅលួចយកអាវនឹងមួកមកពាក់ ហើយកាន់ឈើច្រត់ក្រោកដើរជើងពីរអាការដូចជាមនុស្ស ចូលទៅក្នុងហ្វូងពពែបាន ៗ

ឯពពែទាំងឡាយ ឃើញអាវមួកនឹងឈើច្រត់ដូច្នោះ ក៏នឹកសំគាល់ថាជាម្ចាស់នៃខ្លួន ទើបពុំភិតភ័យភ្ញាក់ផ្អើលដូចកាលមុន ៗ នាំគ្នារកស៊ីស្មៅនូវស្លឹកឈើរៀងខ្លួនទៅ ៗ

ឆ្កែព្រៃតាំងគៀងហ្វូងពពែនោះ ឲ្យចូលទៅក្នុងព្រៃធំគិតថាម្ចាស់វានោះ កាលនឹងគៀង នឹងដេញតែងបញ្ចេញសព្ទថា ហ៊ឿយៗ យ៉ាងនេះ បើដូច្នោះគួរអញបញ្ចេញសព្ទត្រាប់ឲ្យដូចម្ចាស់វា គិតហើយក៏ស្រែកដេញថាហ៊ឿយៗដូច្នេះឯសម្លេងឆ្កែព្រៃដែលស្រែកនោះ មិនដូចសម្លេងមនុស្ស ព្រោះជាជាតិខុសគ្នា សត្វតិរច្ឆានត្រាប់សម្លេងមនុស្សមិនដូច តែស្រែកឡើងក៏ចេញប្រចក្សជាសព្ទឆ្កែព្រៃធម្មតា ទើបពពែទាំង

ឡាយកើតភិតភ័យផ្អើលបោល ស្រែកកងរំពងជាកោលាហល ឡើងៗ ឯនាយគង្វាលពពែនឹងឆ្កែស្រុក បានឮសព្ទពពែផ្អើល ស្រែកយំកង ក៏ភ្ញាក់ចាកនិទ្រាក្រោកម្នីម្នាទៅកាន់ហ្វូងពពែបាន យល់ឆ្កែព្រៃលួចយកអាវមួក នឹងឈើច្រត់របស់ខ្លួនទៅប្រដាប់ ខ្លួនវាធ្វើអាការជាមនុស្សដូច្នោះ នាយគង្វាលពពែក៏បង្អៅឆ្កែ ស្រុកឲ្យដេញខាំឆ្កែព្រៃ ហើយជួយគ្នាវាយឆ្កែព្រៃនោះ ដួល ចុះដល់នូវក្ដីមរណកាលកណ្ដាលព្រៃធំនោះហោង នាយគង្វាល ពពែក៏ដោះយកអាវនឹងមួក អំពីសាកសពនៃឆ្កែព្រៃនោះមក វិញហើយក៏ដេញពពែវិលមកផ្ទះនៃអាត្មាហោងៗ

រឿងនេះ បានគតិដូចមនុស្សចង់សំដែងកាយឲ្យដូចគេអ្នក ជាតិខ្ពស់ ទោះជាធ្វើយ៉ាងណាៗ ក៏គង់មិនដូចគេគង់ចេញកិរិយា ប្រក្រតីខ្លួននោះមកខាងក្រៅឲ្យគេស្គាល់ជាតិខ្លួនបាន ដូចយ៉ាង ឆ្កែព្រៃលួចយកអាវយកមួកគេពាក់ ទាំងកាន់ឈើច្រត់ជាដំបង អាការខាងក្រៅនោះ ធ្វើទៅបានដូចមនុស្សប្រាកដ តែសព្ទ សម្លេងខាងក្នុង ធ្វើទៅពុំដូចមនុស្ស ពួកពពែអាចស្គាល់ជាឆ្កែ ព្រៃទៅបានៗ បទនេះសមដូចពាក្យគតិបុរាណថា "សម្លេង ប្រាប់ភាសា កិរិយាប្រាប់ត្រកូល" ដូចជាតិអ្នកបាសាក់ព្រះត្រ



ពាំង អ្នកសៀមរាប ឬអ្នកប្រទះឡាងជាដើម មនុស្សពួកអស់ នេះ ទោះស្លៀកពាក់តែងរូបកាយប្រដាប់ ដូចអ្នកក្រុងយ៉ាង ណាត្រាប់បាន តែបើហានិយាយឡើងកាលណាសម្លេងនោះ ប្រាប់ឲ្យគេដឹងថា ខ្លួនជាអ្នកបាសាក់ព្រះត្រពាំង សៀមរាប ស្រុកប្រទះឡាង មានអាងនឹងសំនៀងប្រាប់ភាសាខ្លួនស្រាប់ៗ

មួយទៀត លោកអ្នកផ្សេងភាសាគ្នា ទោះចេះនិយាយបាន យ៉ាងណាៗ សំនៀងបែងនោះចេញឲ្យគេដឹងថាអ្នកនេះជាចិន ឆៅ អ្នកនេះជាយួន ជាសៀមជាដើមទៅបានៗ បទអស់នេះ អ្នកប្រាជ្ញគួរពិចារណាទៅទៀតចុះៗ

**ចប់តម្រាគតិអ្នកទាបត្រាប់ភាសាអ្នកខ្ពស់ទី ២៥។**

## រឿងចៅមាណពម្នាក់ចិញ្ចឹមមេឆ្មា១

**និទាននេះមានដំណាលក្នុងក្បួនបារាំងសែស**

មានចៅមាណពម្នាក់ចិញ្ចឹមមេឆ្មា១ ទុកសម្រាប់ឲ្យខាំកណ្ដុរ មេឆ្មានោះមានមារយាទល្អ ចៅមាណពក៏ស្រឡាញ់មេឆ្មានោះ មហិមា តែពេលចូលនិទ្រាកាលណា ក៏ហៅមេឆ្មានោះមកដេក ជាមួយនឹងខ្លួនតែសព្វៗថ្ងៃ មេឆ្មាក៏មានចិត្តស្រឡាញ់ម្ចាស់ ដោយភាពសត្វ ចៅមាណពស្រឡាញ់ឆ្មាខ្លាំង ក៏តាំងអធិដ្ឋាន

សំពះបន់ស្រន់ដល់ព្រះឥសូរថា "ព្រះម្ចាស់ទេវតាអើយសូមមកជួយប្រសិទ្ធិរូបមេឆ្មានេះ ឲ្យក្លាយកាយកើតជាស្រីមនុស្សឡើង ខ្ញុំនឹងយកជាភរិយា" ។

គ្រាកាលនោះ ព្រះឥសូរទេវរាជឮចៅមាណពបានរឭកដល់គុណខ្លួនក៏អាណិតចៅមាណពនោះទើបហោះមកប្រសិទ្ធិមេឆ្មានោះឲ្យកើតកាយក្លាយជាស្រីក្រមុំ ហើយផ្សំផ្គុំឲ្យជាភរិយានៃចៅមាណពនោះឯង ។

ឯចៅមាណពនោះ កាលសមក្តីប្រាថ្នាហើយក៏មានចិត្តត្រេកអរសាទរក្រៃពេកណាស់ ចាប់ដើមពីថ្ងៃនោះ អ្នកទាំងពីរក៏បាននៅរួមសុខទុក្ខជាប្តីប្រពន្ធនឹងគ្នា រកស៊ីចិញ្ចឹមជីវិតដោយភារៈជាអ្នកស្រែចំការតាមធម្មតាលោកិយ ។

ថ្ងៃមួយជាពេលរាត្រី ប្តីប្រពន្ធក៏ចូលនិទ្រាលើគ្រែជាមួយគ្នា កាលនោះមានកណ្តុរ២ តួវាវារមកខាងនាងភរិយានោះ នាងនោះដោយជាតិជាឆ្មាតែងធ្លាប់ចាប់កណ្តុរ លុះកណ្តុរវាវារមកខាងខ្លួន ក៏ស្ទុះក្រោកលោតលោតទៅចាប់កណ្តុរដោយរហ័ស ធ្លាក់ចុះអំពីគ្រែ បោកក្បាលទៅលើជើងគ្រែ ។ ឯចៅប្តីក៏ភ្ញាក់ក្រោកម្នីម្នា ស្ទុះប្រញាប់ចាប់បានជើងនាងប្រពន្ធហើយលើក



ឡើងតាំងបបក់ព្រលឹងលួង លោមសួរថា "ហែមាសពីសីមានហេតុអ្វីបានជាប្អូនក្រោកលោតចេញអំពីទីដំណេកដូច្នេះ" ។

ឯនាងនោះដឹងខ្លួន ក៏កើតក្តីអៀនខ្មាសប្តីបិទសេចក្តីនោះមិនសំដែងឲ្យប្តីដឹងឡើយ ឆ្លើយបង្វែងថាខ្លួនយល់សប្តិមើទៅផ្តាស ពុំដឹងខ្លួនប្រាណសោះឡើយ ។ ឯកិរិយានាងឆ្មាប្រព្រឹត្តក្រោកចាប់កណ្តុរនោះមិនមែនតែ១ វេលានោះទេគឺតែដេកលក់ហើយមានកណ្តុរវាទៅខាងខ្លួនកាលណា តែងស្ទុះក្រោកលោតចាប់កណ្តុរក្នុងកាលនេះឯង នាងឆ្មាប្រព្រឹត្តយ៉ាងនោះតែទៀងៗមក ទាល់តែចៅប្តីមិនហ៊ានឲ្យដេកលើគ្រែ នាំឲ្យដេកតែនៅទីផ្ទៃរាបដរាបអស់អាយុនឹងគ្នា ត្រាតែទៅតាមយថាកម្មហោង ។

រឿងនេះ បានគតិជាតិលះវាស្នាខ្លួនចោលពុំបានគឺខ្លួនធ្លាប់សន្សំនូវអារម្មណ៍ ពីដើមយ៉ាងណាមកអារម្មណ៍នោះជាប់តាមមិនដាច់ លះបង់ទៅពុំបានដូចធ្លាប់លេងល្បែងនានា មានល្បែងលេងចំបាប់ប្រដាល់ជាដើម ទោះដល់ខ្លួនចាស់ជរាហើយលើកលែងល្បែងនោះចេញក្តី បើមានអ្នកឯណាមួយទៅនិយាយត្រូវត្រង់អារម្មណ៍ខ្លួនធ្លាប់ប្រព្រឹត្តមកនោះ ក៏កើតចិត្តលោភ

ឡើងសំដែងនូវកិរិយាល្បែងនោះអួតបង្ហាញឲ្យគេបានដឹងបានឮឡើងជាប្រាកដ ៗ

មួយទៀត បុគ្គលកើតក្នុងវង្សត្រកូលដែលមានកិរិយាយ៉ាងណា កិរិយានោះជាប់តាមសន្តានចិត្ត នឹងគិតលះបង់ចោលបានដោយក្រ កិរិយាមារយាទជាកំណើតកើតមកសម្រាប់រូបកាយនេះ សឹងប្រព្រឹត្តទៅជាផ្លូវ ជាគន្លងចេញឲ្យគេយល់គេស្គាល់បានក្នុងកាលប្រជុំជន ៗ បទនេះសមដោយពាក្យបុរាណថា "ត្រកូលសជាតិ មារយាទសពូជ" អធិប្បាយថា ជាតិកំណើតល្អអាក្រក់ សឹងប្រព្រឹត្តទៅតាមត្រកូលមែនត្រកូលអ្នកល្អក៏កើតជាតិល្អ មិនលះបង់ជាតិល្អជាតិបណ្ឌិតទៅបាន ទោះធ្លោយធ្លាក់ចុះជាអ្នកក្រីក្រក្តី ក៏លះបង់មារយាទល្អទៅពុំបាន នៅមានមារយាទល្អដដែល ៗ

បទនេះ បានដូចបទបាលីក្នុងគម្ពីរលោកនីតិថា៖

សុក្ខោបិ ចន្ទនតរុ ន ជហាតិ គន្ធំ
នាគោ គតោរណមុខេ ន ជហាតិ លីឡំ
យន្តេ គតោ មធុរសំ ន ជហាតិ ឧច្ឆុ
ទុក្ខោបិ បណ្ឌិតជនោ ន ជហាតិ ធម្មំ។



ប្រែថា ជាតិខ្លឹមចន្ទន៍ទោះក្រៀមស្វិតក្រញង់មិនលះបង់ក្លិនក្លែបសុគន្ធា ដំរីសារទោះចូលសឹកយុទ្ធនា មិនលះបង់លីលាល្អាយល្អងក្រាយ ៗ ជាតិអំពៅទោះនៅក្នុងយន្តគាប មិនលះបង់សភាពរសផ្អែមសាយ ជាតិបណ្ឌិតទោះមានទុក្ខក្នុងកាយ មិនជិនណាយលះបង់ព្រះធម៌ថ្លៃ ៗ

**ចប់តម្រាគតិបង់ភាស្នាំរួចទី ២៦។**

## រឿងចៅមាណពម្នាក់ចិញ្ចឹមសុនខតឿ១

មានចៅមាណពម្នាក់ចិញ្ចឹមសុនខតឿ១ ជាទីប្រើប្រាស់ក្នុងការនាំយកវត្ថុអ្វីៗទៅបាន ថ្ងៃមួយចៅមាណពទៅព្រៃដើម្បីកាប់ឈើរើព្រៃ ធ្វើចំការពោតបានផ្តាំភរិយាថា ខ្លួនទៅចំការមុន ចាំដល់ពេលថ្ងៃបន្តិចឲ្យយកកញ្ចប់បាយចងកឆ្កែ ឲ្យវានាំយកទៅឲ្យខ្លួនជាក្រោយ ផ្តាំស្រេចហើយចៅនោះក៏ទៅចំការឯព្រៃធ្វើការតាមភាពខ្លួន ៗ

ឯនាងភរិយា លុះដល់ពេលក៏ចំអិនអាហារបានហើយទើបរៀបចាត់ចែងវេចជាបង្វេចហើយ ចងនឹងកឆ្កែតឿប្រាប់ថា ចូរអានាំអាហារនេះ ទៅឲ្យម្ចាស់អាឯចំការឯណោះឲ្យឆាប់ ឯឆ្កែនោះក៏ទទួលពាក្យហើយ បោលតម្រង់ទៅឯចំការលុះទៅ

ដល់អូរមានទឹកខណ្ឌនៅទឹកនោះជ្រៅ សុនខនឹងលុយឆ្លងទៅពុំរួចរកទីទួលគោក ទីទឹករាក់ឬទូកក្តារឆ្លងពុំបាន ពេលសោតក៏ជួនថ្ងៃជិតត្រង់ សុនខក៏ប្រថុយលោតហែលឆ្លងទៅដោយកំលាំងរហ័ស ឯអាហារក្នុងបង្វេចនោះក៏ទទឹកទាំងអស់ លុះទៅដល់ម្ចាស់ក៏បោលចូលទៅទៀបជិត ។

ឯចៅមាណព ស្រាយយកបង្វេចបាយអំពីកឆ្កែ ឃើញបាយនោះទទឹកជោកដូច្នោះ ក៏ខឹងនឹងសុនខទើបចាប់ដំបងសំពង ២-៣ ដំបងយ៉ាងដំណំ ហើយផ្ទាលដោយប្រការផ្សេងៗ ឯសុនខនោះលុះត្រូវនាយវាយដូច្នោះ ក៏ឈឺចិត្តអាណិតខ្លួនក្រៃពេកទើបបោលចេញចាកទីនោះ ហើយគិតថាអញនេះជាសុនខកបកម្លាំងខ្លាំងពូកែហើយ ឥឡូវអាដំបងនោះវាពូកែលើសឯងទៅទៀត គឺវាអាចប្រហារក្បាលឯងបានជាម្តង បើដូច្នេះគួរតែអញអធិដ្ឋានបន់ទេវតា ឲ្យលោកជួយប្រសិទ្ធិកាយអញនេះឲ្យក្លាយទៅជាដំបងវិញ គិតហើយសុនខក៏អធិដ្ឋានថា "ព្រះឥសូរជាម្ចាស់អើយ សូមមេត្តាប្រោសធ្វើរូបកាយខ្ញុំ ឲ្យកើតជាដំបងហោង" ។

កាលនោះ ព្រះឥសូរទេវតាក៏មកប្រសិទ្ធិកាយសុនខនោះឲ្យ



កើតជាដំបង សំរេចដូចបំណងនៃឆ្កែតឿនោះឯង ឯដំបងសុនខចាប់ផ្តើមពីនោះមក ក៏តាំងតែហោះហើរដើរ វាយគេវាយឯងឥតឈប់ឈរ គឺវាយមនុស្សនូវសព្វទួទៅទាំងពិភព ។

ឯមនុស្សនឹងសត្វទាំងឡាយ បានក្តីក្តៅក្រហាយទាំងអស់គ្នា ទើបនាំគ្នាឡើងទៅប្តឹងដល់ព្រះឥស្សរាធិបតី តាមដំណើរដែលដំបងសុនខបៀតបៀននោះឯង ។ ព្រះឥសូរក៏បណ្តាលឥទ្ធិឫទ្ធិ និម្មិតជាភ្លើងឆេះប្រហារដំបងនោះចេញ ។ ឯដំបងសុនខឃើញភ្លើងឫទ្ធិមកដុតអាត្មាដូច្នោះ ក៏នឹកថាអញជាដំបងថាមានឫទ្ធិខ្លាំងពូកែហើយ ឥឡូវមានភ្លើងខ្លាំងពូកែលើសអញទៀត "ឱ ព្រះជាម្ចាស់ខ្ញុំអើញ សូមមេត្តាប្រោសឲ្យខ្ញុំកើតជាភ្លើងវិញហោង" ។

ព្រះឥស្សរាធិបតី ក៏ធ្វើដំបងសុនខនោះឲ្យកើតជាភ្លើងតាមទំនើងក្តីប្រាថ្នានៃសុនខ ឯភ្លើងសុនខចាប់ដើមតាំងពីកើតឡើង ក៏ដើរដុតឆេះព្រៃព្រឹក្សាលតាវល្លិនូវទីភូមិលំនៅទួទៅទាំងពិភព ពុំមានឈប់ឈរឡើង ។

ឯមនុស្សនឹងសត្វទាំងឡាយ បានក្តីក្តៅក្រហាយទាំងអស់គ្នា ទើបនាំគ្នាទៅក្រាបទូលប្តឹងដល់ព្រះឥសូរតាមរឿងនោះឯង ។

ព្រះឥសូរក៏បណ្ដាលឫទ្ធិឲ្យកើតជាភ្លៀងបង្អុរធ្លាក់ចុះមកលត់ភ្លើងសុនខនោះ ។ ភ្លើងសុនខគិតថា ភ្លើងអញនេះអាចហានខ្លាំងពូកែណាស់ហើយ ឥឡូវមានទឹកភ្លៀងវិសេសលើសវិញ "ឱ ព្រះម្ចាស់ខ្ញុំអើយ សូមឲ្យខ្ញុំកើតជាភ្លៀងវិញចុះ" ។

ព្រះឥសូរក៏បណ្ដាលឲ្យភ្លើងសុនខប្រែកើតជាភ្លៀងតាមក្ដីប្រាថ្នា ឯភ្លៀងសុនខចាប់ដើមតាំងពីកើតឡើង ក៏ចេះតែបង្អុរភ្លៀងធ្លាក់ជន់ជោរលិចព្រៃលិចភូមិស្រែចំការនានា ។

មនុស្សនឹងសត្វបានក្ដីក្ដៅក្រហាយទីទៃៗ ទើបនាំគ្នាឡើងប្ដឹងដល់ព្រះឥសូរ ។

ព្រះឥសូរក៏បណ្ដាលឫទ្ធីឲ្យកើតជាខ្យល់បោកផាត់បង្ហួតទឹកភ្លៀងឲ្យហែងហួតបាន ។ ឯភ្លៀងសុនខឃើញខ្យល់មានអំណាចខ្លួនដូច្នោះ ក៏អធិដ្ឋានថា "ព្រះម្ចាស់ខ្ញុំអើយ សូមមេត្តាប្រោសឲ្យខ្ញុំកើតជាខ្យល់វិញទៅ" ។

ព្រះឥសូរ ក៏ធ្វើភ្លៀងឲ្យកើតជាខ្យល់តាមក្ដីប្រាថ្នានៃសុនខនោះឯង ។ ឯខ្យល់សុនខចាប់ដើមពីកើតឡើងមក ក៏តាំងតែបោកផាត់បំបាក់អស់ឈើព្រៃព្រឹក្សាលតាន់ល្លិទ្ធទៅសព្វឋានឈើទាំងឡាយធន់ពុំបាននឹងកំលាំងខ្យល់សុនខ សឹងបោកបក់



បោកផាត់បំបាក់អស់ឈើព្រៃព្រឹក្សាលតាន់ល្លិទ្ធទៅសព្វឋានឈើទាំងឡាយធន់ពុំដួលរលើងរលំទៅផ្សេងៗ នៅសល់តែដំបូកស្អួយ១ ដុះកណ្ដាលវាលពុំកក្រើករំពើកឡើយ ។ ឯខ្យល់សុនខបានឃើញដំបូកស្អួយនោះ ពុំកក្រើកដោយកំលាំងខ្លួនដូច្នោះ ក៏គិតថាដំបូកនេះខ្លាំងពូកែលើសអាត្មា គួរតែប្រាថ្នាឲ្យកើតជាដំបូកវិញប្រសើរវិសេសជាងខ្យល់នេះ គិតហើយសុនខអធិដ្ឋានថា "ព្រះម្ចាស់ខ្ញុំអើយមេត្តាប្រោសឲ្យខ្ញុំកើតជាដំបូតវិញហោង" ។

ឯព្រះឥសូរក៏ប្រសិទ្ធខ្យល់សុនខ ឲ្យកើតជាដំបូកស្អួយ១ ដុះឡើងនៅកណ្ដាលទីវាល ។ គ្រាកាលនោះ មានមហិង្ស១ ទៅរកស៊ីស្មៅ នៅទីទៀបខាងដំបូក ក្របីនោះវារមាស់ក្បាលកីជល់វីធដំបូកនោះបែកបាក់ធ្លាក់ចុះ ឯដំបូកសុនខគិតថាអាសត្វមហិង្សនេះ វាខ្លាំងពូកែលើសដំបូកនេះទៅទៀត បើដូច្នេះគួរអញអធិដ្ឋានឲ្យកើតជាមហិង្សវិញ គិតហើយអធិដ្ឋានថា "ព្រះម្ចាស់ខ្ញុំអើយ សូមមេត្តាធ្វើឲ្យខ្ញុំកើតជាសត្វមហិង្សវិញ" ។

ឯព្រះឥសូរក៏ធ្វើដំបូកសុនខនោះឲ្យកើតជាសត្វមហិង្សតាម

ក្ដីប្រាថ្នា ៗ ឯមហិង្សាសុនខចាប់ដើមពីកើតឡើងមក ម្ចាស់នឹងប្រើប្រាស់ពុំសូវបាន ជាក្របីទាញទង់ណាស់ ចងនឹងខ្សែអ្វី ៗ ពុំជាប់ឡើយ ទើបម្ចាស់នោះយកព្រ័ត្រ ៣ ផ្លុងទៅចង់កទើបជាប់បានមហិង្សាសុនខ ទាញកន្ត្រាក់ព្រ័ត្រនោះពុំដាច់ឡើយ ហើយគិតថា អាព្រ័ត្រនេះ វាពូកែ លើសអញទៅទៀត "ឱព្រះម្ចាស់ខ្ញុំអើយ សូមមេត្តាប្រោសឲ្យខ្ញុំកើតជាព្រ័ត្រទៅវិញចុះ" ៗ

ព្រះឥសូរក៏ប្រសិទ្ធិឲ្យកើតជាព្រ័ត្រ តាមដោយសេចក្ដីប្រាថ្នានៃចៅសុនខគ្រាកាលនោះមានឆ្កែតឿ ១ចូលទៅឃើញចង្វាយព្រ័ត្រ ក៏កន្ត្រៀមស៊ីដាច់ជាកំណាត់ធំកំណាត់តូច ឯព្រ័ត្រសុនខ ឃើញឆ្កែតឿវាកកេរស៊ីព្រ័ត្រដូច្នោះ ក៏នឹកថាអាសុនខនេះវាខ្លាំងពូកែលើសព្រ័ត្រទៅទៀត "ឱព្រះជាម្ចាស់ខ្ញុំអើយ សូមមេត្តាប្រោសធ្វើខ្ញុំឲ្យកើតជាឆ្កែតឿវិញចុះ" ៗ

ព្រះឥសូរក៏មកប្រសិទ្ធិព្រ័ត្រនោះឲ្យកើតជាសុនខតឿដូចក្ដីប្រាថ្នា ចៅសុនខក៏បែរហក់ចុះមកជាឆ្កែតឿដូចមុនវិញហោង ៗ

រឿងនេះ បានគតិដល់បុគ្គលអ្នកប្រាថ្នាចង់តែបានវត្ថុអ្វី ៗ



ពុំដឹងវត្ថុនោះជាសត្រូវធ្លាក់មកត្រូវលើខ្លួនឯងវិញ ៗ

មួយទៀតហៅថា ប្រាថ្នាហួសសំណាង ហួសជាតិហួសកំណើតប្រព្រឹត្តទៅមិនផុតឧបនិស្ស័យបទនេះអ្នកប្រាជ្ញគួរគប្បីពិចារណាទៅទៀតចុះ ៗ

**ចប់តម្រាប្រាថ្នាហួសសំណាងទី ២៧។**

## រឿងឆ្កែវង្វេងម្ចាស់នឹងមហាឥសី

មានសុនខ១ ទៅលេងព្រៃជាមួយនឹងម្ចាស់វង្វេងបាត់ម្ចាស់ក្នុងព្រៃអត់បាយ ៣ ថ្ងៃពុំបានជួបប្រទះនឹងមនុស្សម្នាក់ឡើយ វង្វេងដើរដល់ព្រៃហិមពាន្តបានឃើញអាស្រមសាលា ព្រមហាឥសី អ្នកសាងព្រឹទ្ធតាំងនៅទី១ ក៏ចូលទៅនៅអាស្រ័យនឹងមហាឥសីនោះ ព្រះមហាឥសីក៏មេត្តាអាណិតឲ្យទានអាហារដែលសេសសល់អំពីលោក គឺអាហារដែលបានមកពីសាច់ឆ្អឹងសត្វជាសាច់សំណល់អំពីរាជសីហ៍ ខ្លា ឬ សត្វហត្ថីលិង្គជាដើមនោះ ៗ

សុនខនោះក៏បាននៅជាសុខសប្បាយ ពុំបានគិតវិលទៅស្រុកវិញឡើយ ឯព្រះមហាឥសីថ្ងៃ១ លោកគិតថា សុនខនេះជាជាតិសត្វស្រុក អាស្រ័យចិញ្ចឹមជីវិតដោយសារតែមនុស្ស ឥឡូវមកនៅនឹងអញជាអ្នកនៅព្រៃ អាស្រ័យតែផ្លែឈើមើមឈើជា

អាហារនឹងបានបាយត្រីសាច់ឯណាចិញ្ចឹមវា មួយទៀតជាតិសត្វ
ស្រុកនឹងមកនៅព្រៃឯណាក៏បាន ព្រោះព្រៃសឹងប្រកបដោយ
ភ័យអន្តរាយ កើតអំពីពាឡម្រឹគមានខ្លារាជសីហ៍ជាដើម បើ
ដូច្នេះ គួរតែអញប្រសិទ្ធិកាយសុនខនេះ ឲ្យក្លាយទៅជារាជសី
ហ៍គ្រាន់គ្នាបាននៅអាស្រ័យជាមួយ នឹងហ្វូងសីហៈផងទាំងឡាយ
គិតហើយព្រះមហាឥសី ហៅឆ្កែនោះមកជិតហើយតាំងបរិកម្ម
ព្រះគាថា ប្រសិទ្ធិរូបសុនខឲ្យក្លាយជាកាយសីហៈឡើងបាន១
រំពេច ឯសិហសុនខបានសំរេចក្ដីប្រាថ្នាហើយ ក៏ត្រេអរសាទរ
ក្រៃពេកទើបក្រាបលាព្រះមហាមុនី ចរលីលាបោលចូលព្រៃ
ទៅនៅអាស្រ័យនឹងហ្វូងសិហៈទាំងឡាយក្នុងព្រៃ១ លុះនៅយូរ
មក ចៅសីហសុនខចង់បាននាងរាជសីហ៍ជាកូនក្រមុំចៅកេសរ
រាជសីហ៍ ទើបចូលទៅនិយាយដណ្ដឹងតកេសររាជសីហ៍ជាបិតាថា
"បពិត្រលោកដ៏ចំរើន! ខ្លួនខ្ញុំបាននេះ មានចិត្តប្រតិព័ទ្ធស្រឡា
ញ់កូនក្រមុំលោកជាភរិយា សូមលោកប្រោសមេត្តាដល់ខ្ញុំបាទ
ចុះ"ៗ ឯកេសររាជសីហ៍ឮដូច្នោះក៏តបថា "អើចៅៗស្រឡាញ់
កូនយើងៗក៏ឥតបើថាអ្វី ព្រោះការលោកិយតែងមានជាធម្មតា
តែថាពួកយើងពុំទាន់ស្គាល់ពូជពង្សវង្សចៅឯងនេះឡើយមិន



ដឹងជាពូជធារចៅឯងតើដូចម្ដេច បើដូច្នេះចាំយើងទៅសួរដល់
ព្រះមហាឥសីជាម្ចាស់ឯងសិន"ៗ ឯចៅសិហសុនខបានឮកេសរ
រាជសិហ៍ ថាចាំទៅសួរពូជពង្សខ្លួននឹងព្រះឥសីដូច្នោះក៏គិតថា
អាត្មាអញចេះជាជាតិពូជសុនខពិតឥឡូវគេថា នឹងទៅសួរដល់
ព្រះមហាឥសីៗ សោតលោកជាអ្នកកាន់សីលសាងព្រឹទ្ធ បើគេ
សួរលោកហើយ កាលណាឡើយលោកនឹងលាក់កេរ្ដិ៍អញនេះ
បាន គង់លោកប្រាប់គេដោយត្រង់ថាអញជាជាតិសុនខពិត
កាលបើគេដឹងថាអញជាជាតិសុនខហើយម្ដេចឡើយគេនឹងឲ្យ
កូនក្រមុំគេនោះ ជាភរិយអញបើដូច្នេះ មានតែអញទៅខាំ
សម្លាប់មហាឥសីនោះចេញជាការកាត់ផ្លូវមិនឲ្យពួកអស់នេះ
ទៅសួរ ទៅបញ្ជាក់បាន គិតហើយសីហសុនខលាកេសរសីហៈ
ម្នីម្នា បោលទៅកាន់សំណាក់ព្រះឥសី ដល់ហើយក៏សំញេញ
ធ្មេញ បញ្ចេញសព្ទសំដែងអាការ នឹងលោតទៅខាំព្រះ
មហាឥសីៗ បែរទៅយល់អាការកិរិយាសីហសុនខដូច្នោះ ក៏
ជ្រាបហេតុនោះមួយរំពេចទើបគិតថា អាសត្វនេះកោងកាច
ណាស់វាគិតនឹងមកសម្លាប់ឯងវិញ បើដូច្នេះនឹងទុកវាជារាជសីហ៍
តទៅឯណាបាន គួរប្រសិទ្ធិកាយវាឲ្យក្លាយទៅជាឆ្កែដូចដើម

វិញគិតហើយព្រតាបសតាំងពិធីប្រសិទ្ធកាយសីហៈនោះឲ្យក្លាយទៅជាសុនខដូចកាលមុនហោង ៗ ឯសីហសុនខនោះ លុះប្រែកាយក្លាយកើតជាឆ្កែវិញដូច្នោះ ក៏កើតក្ដីអៀនខ្មាសក្ដៅចិត្តនឹងស្ថិតនៅក្នុងសំណាក់ព្រះតាបសនោះពុំបាន ក៏បោលបោលលំនៅរត់ទៅតាមយថាកម្មនៃអាត្មាវិញហោង ៗ

រឿងនេះ បានគតិដល់បុគ្គលអកតញ្ញូមិនដឹងគុណលោកអ្នកមានគុណលើខ្លួន បាននូវទុក្ខវេទនាក្ដៅក្រហាយចិត្តប្រចក្សក្នុងលោកនេះ ៗ

មួយទៀត ជាតិអ្នកថោកទាបហើយទោះបីលោកលើកខ្លួនឡើងក៏លូតខ្ពស់ទៅពុំបាន សន្ដានទាបក៏ទាបនៅដដែលវិញ ក្នុងបទលោកថា អស្រ័យកំណើតម៉ែឪថោកទាប ដូចមានបទបាលីក្នុងគម្ពីរលោកនីតិថា៖

មាតា ហីនស្ស ទុភាសា
បិតា ហីនស្ស ទុក្រិយា
ឧភោ មាតាបិតហោហិ
ជាទុភាសា ច ទុក្រិយា។



ប្រែថា បើមាតាហីនជាតិកើតបុត្រា បុត្រនោះមានវាចាភាសាទាប ៗ បើបិតាហីនជាតិមាត្រទុរភាពបុត្រនោះទាបកិរិយាអាក្រក់នៅ បើម៉ែឪហីនជាតិទាំងពីរនាក់ បុត្រនោះអប្បលក្ខណ៍ទាំងពីរផ្លូវ ទាំងកិរិយាភាសាក៏ហ្វងសៅ តាមគន្លងម៉ែឪផ្លូវដូចគ្នាមួយទៀតថា៖

ទុជនោ ទោសមាលាយ
ទុកាដូមិរ សូការោ
សុជនោ សុគុណាក្កាហោ
ហំសោរ វីរមិច្ឆតា។

ជនជួកាន់យកតែទោសទុក្ខ ដូចកលជ្រូកស្រុកប៉ងអាចម
ជនល្អកាន់យកគុណឧត្ដម ដូចហង្សប៉ងចំចឹកទឹកដោះ ៗ

**ចប់តម្រាគតិជនជួអកតញ្ញូទី ២៨។**

## រឿងឧកញ៉ាយោមរាជនឹងឧកញ៉ាពលទេព

មាននាហ្មឺន២នាក់ ម្នាក់ជាទីឧកញ៉ាយោមរាជម្នាក់ទៀតជាឧកញ៉ាពលទេព ឯឧកញ៉ាពលទេពជាមនុស្សលោភបុណ្យសក្ដិចង់បានទីយោមរាជកើតស្អប់ឧកញ៉ាយោមរាជ គិតស្វែងរកទោសដាក់នឹងក្រាបទូលទំលាក់ចាកទីយោមរាជ អាត្មាឯងនឹងបាន

ស្តីទីឃោមរាជនោះតទៅឧកញ៉ាពលទេពស្វែងរកទោសលោកឃោមរាជនោះជាយូរខែមក ថ្ងៃមួយមានអ្នកទោសម្នាក់មានទោសធ្ងន់ ក្រុមជំនុំកាត់ទោសដល់ប្រហារជីវិត ។ ឯអ្នកទោសនោះដឹងថាថ្ងៃព្រឹកស្អែកនេះហើយ គេនឹងនាំអាត្មាទៅសម្លាប់ជាប្រាកដក៏តាំងសៅសោករិះយោគ ស្តាយជីវិតមហិមាយំពណ៌នាថា "ឱជីវិតអញអើយ! ព្រឹកស្អែក១នេះនរណាឡើយនឹងទៀវបង់បាន តែកើតឡើងហើយ រមែងតែងស្លាប់ជាធម្មតាតែថាត្រង់ជីវិត១នេះ ទោះបង់បាត់ទៅក្តី ក៏មិនសូវជាសោកស្តាយអ្វីប៉ុន្មាន មកសោកស្តាយតែវិជ្ជា១ដែលខ្លួនបានចេះហើយ ពុំទាន់បានបង្ហាត់បង្ហាញនរណាមួយសោះ អស់មាននរណាមួយក្នុងលោកនេះ អាចចេះតទៅទៀតបានឡើយ" ។

កាលនោះមាននាយភូឃុំម្នាក់បានឮ ចៅនោះយំពណ៌នាសោកស្តាយវិជ្ជាដូច្នោះ ក៏ចូលទៅសាកសួរថា "ចៅឯងព្រឹកនេះដល់ទីស្លាប់ប្រាកដហើយ ចៅយំរៀបរាប់ថាត្រង់ជីវិត រូបកាយមិនសូវជាស្តាយប៉ុន្មានមកស្តាយតែវិជ្ជា១ ដែលចេះមក តើវិជ្ជានោះឈ្មោះវិជ្ជាអ្វី ចៅចេះវិជ្ជាអ្វី ចូរប្រាប់យើងមើល" ។

ឯអ្នកទោសក៏ប្រាប់ថា "ខ្ញុំបានចេះវិជ្ជាដឹងភាសាសត្វវិជ្ជានេះ



វិសេសរបស់ខ្ញុំបានណាស់ ក្នុងលោកនេះគ្មាននរណាចេះសោះ តែខ្ញុំបានដល់ទីស្លាប់ហើយវិជ្ជានោះសូន្យជាម្តង ព្រោះពុំមាននរណាបានមករៀនតទៅឡើយ" ។ នាយភូឃុំឮដូច្នោះហើយនាំសេចក្តីនុះទៅជំរាបលោកឧកញ៉ាឃោមរាជសព្វប្រការ ឯឧកញ៉ាឃោមរាជក៏នឹកក្នុងចិត្តថា វិជ្ជានេះវិសេសក្រៃពេកណាស់គួរតែរៀនយកទើបនាំនាយភូឃុំទៅដោះអ្នកទោសចាកគ្រឿងចាំ ហើយសួរបញ្ជាក់ជាពិតឬពុំពិត ឯអ្នកទោសក៏ជំរាបថាចេះពិតប្រាកដមែន ឧកញ៉ាឃោមរាជថាយើងសុំរៀនតពីចៅឯងតើបានឬមិនបាន វិជ្ជានេះដម្លៃប៉ុន្មាន ។

អ្នកទោសថាខ្ញុំបាទ ជូនព្រះតេជព្រះគុណបានសូមព្រះតេជព្រះគុណរៀនតទៅចុះ តែអត់អំពីខ្ញុំប្របាទនេះហើយវិជ្ជានោះនឹងសូន្យជាប្រាកដតែការនឹងរៀននោះតោងទៅតាំងពិធីរៀន នៅក្នុងព្រះវិហារចំពោះព្រះភក្ត្រព្រះបដិមាករជាប្រធាន ក៏ឯគ្រឿងកំណល់គ្រូនោះមិនមានអ្វីច្រើនទេ ត្រូវការតែទៀន៥ ធូប៥ ផ្កា៥ប៉ុណ្ណោះឯង អញ្ជើញព្រះតេជព្រះគុណរៀបរៀនឲ្យឆាប់ចុះ តែព្រឹកស្អែកខ្ញុំប្របាទលាព្រះតេជព្រះគុណទៅស្រុកខ្មោចហើយ ។

ឧកញ៉ាយោមរាជក៏ធ្វើតាមទើបឲ្យនាយភូឃុំនាំខ្លួនអ្នកទោសទៅឯវត្ត ដល់ហើយក៏នាំចូលទៅក្នុងព្រះវិហារ ឲ្យបិទទ្វារវិហារជិតទាំងអស់ ពុំឲ្យមនុស្សណាមួយឮឡើយ ឧកញ៉ាយោមរាជក៏រៀបទៀនធូបលាជផ្កាតាំងនៅចំពោះព្រះភក្ត្រព្រះ ហើយថាវិធីវៀននោះតើដូចម្ដេចខ្លះ ចូរទៅបង្គាប់ទៅមើលយើងនឹងធ្វើតាម អ្នកទោសបង្គាប់ឲ្យអុជទៀនធូបហើយឲ្យលោកយោមរាជ នឹងខ្លួនវាក្រាបថ្វាយបង្គំព្រះ សូត្រនមស្សការពុទ្ធគុណ ធម្មគុណ សង្ឃគុណ ចប់ចុះហើយ អ្នកទោសប្រណម្យដៃពោលដង្ហោយឡើយថា "ឱព្រះដ៏មានបុណ្យព្រះគុណប្រកបដោយព្រះមហាករុណា តែងប្រោសមេត្តាសត្វ ដែលកើតមានក្ដីវិបត្តិចូលមកពឹងពោធិសម្ភារ ជួយដោះទុក្ខសត្វឲ្យសត្វបានក្ដីសម្រាន្តទាំងលោកនេះនឹងបរលោក ព្រះគុណអើយខ្លួនខ្ញុំព្រះករុណានេះត្រូវទោសធំ ព្រឹកស្អែកនេះហើយលោកឧកញ៉ាយោមរាជ នឹងឲ្យនាំទៅប្រហារជីវិតខ្ញុំព្រះករុណាៗមានក្ដីភិតភ័យខ្លាចក្ដីស្លាប់នោះជាបំផុត ស្ដាយជីវិតក្រៃពេកណាស់ ព្រះគុណអើយ សូមព្រះអង្គទ្រង់ប្រោសបិណ្ឌបាតជីវិតខ្ញុំព្រះករុណាអំពីលោកឧកញ៉ាយោមរាជនេះ ឲ្យលោកប្រោសលែង



ខ្ញុំឲ្យរួចចាកក្ដីស្លាប់ក្នុងគ្រាម្ដងនេះថាហើយ អ្នកទោសវាទៅក្រាបទៀបបាទជើងលោកយោមរាជហើយដង្ហោយថា "ឱព្រះតេជព្រះគុណអើយ! សូមប្រោសអត់ទោសខ្ញុំប្របាទចេះ ហេតុដែលខ្ញុំប្របាទយំសោគពោលថា ស្ដាយវិជ្ជាចេះភាសាសត្វនោះខ្ញុំមិនចេះវិជ្ជានោះទេតើខ្ញុំសោកស្ដាយជីវិតពិតៗ គិតបញ្ឆោតឲ្យព្រះតេជព្រះគុណ អញ្ជើញមកកាន់ព្រះវិហារនេះឯងដើម្បីឲ្យព្រះសម្មាសម្ពុទ្ធជាម្ចាស់ពគីព្រះពុទ្ធរូបនេះឯង ទ្រង់បិណ្ឌបាតជីវិតខ្ញុំប្របាទ អំពីព្រះតេជព្រះគុណ ឱព្រះតេជព្រះគុណអើយប្រោសថ្វាយជីវិតខ្ញុំប្របាទ ដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទៅឥឡូវព្រះអង្គទ្រង់បិណ្ឌបាតហើយ ព្រះគុណអើយ! ការបូជាដោយគ្រឿងអាមិសទានឯទៀតៗនោះមានផលានិសង្ស ពុំស្មើនឹងការបូជាជីវិតខ្ញុំប្របាទ ដល់ព្រះពុទ្ធជាម្ចាស់ក្នុងគ្រានេះឡើយ ផលនេះហើយជាផលយ៉ាងធំបំផុត ព្រះតេជព្រះគុណនឹងប្រាថ្នាសាងជាពុទ្ធភូមិ ឬអរហន្តភូមិក៏អាចសម្រេចដូចក្ដីប្រាថ្នាសាងជាពុទ្ធភូមិ ឬអរហន្តភូមិក៏អាសម្រេចដូចក្ដីប្រាថ្នាទៅអនាគតកាល" ៧ ឯលោកឧកញ៉ាយោមរាជ លុះឮពាក្យអ្នកទោសពោលដង្ហោយដូច្នោះ ក៏ដូចជាគេខ្ទាស់ណែនឱរានឹកឃើញថា

ចាញ់ កលឧបាយអ្នកទោសជាប្រាកដ ទើបនិយាយទៅកាន់នាយភូឃុំថា "អើ យើងចាញ់កលអ្នកទោសនេះហើយ ឥឡូវវាពោលពាក្យដង្ហោយសូមជីវិតវាតព្រះពុទ្ធរូប វាអង្វរព្រះពុទ្ធថាឲ្យទ្រង់បិណ្ឌបាតទោសវាតងងជាម្ដង ការនេះតែយើងមិនលែងវា ក៏ដូចជាយើងមិនយល់ដល់ព្រះពុទ្ធជាម្ចាស់ហាក់ដូចជាយើងឥតសទ្ធា ក្នុងព្រះពុទ្ធសាសនាបើដូច្នេះនាយភូឃុំ យើងពីរនាក់ចូលសទ្ធាលើកជីវិតវាថ្វាយដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ចុះ ហើយយើងពីរនាក់ទទួលកែខៃជាក្រោយ គឺយើងបិទបាំងឲ្យជិតកុំឲ្យខ្ចរខ្ចាយឮដល់ត្រចៀកអ្នកដទៃឯទៀតឡើយ" ៗ

ឯនាយភូឃុំក៏ព្រមតាម ទើបលោកឃោមរាជឲ្យនាយភូឃុំស្រាយគ្រឿងចង់ហើយថា យើងលែងចៅឯងហើយ ចូរចៅឯងរត់ទៅនៅទីណាមួយគួររក្សាជីវិតចៅឯងចុះ ហើយកុំនិយាយប្រាប់គេថាយើងដោះលែងចៅឯង ចៅឯងចូរថាកាច់ច្រវាក់រត់ចាកគុកទៅចុះ តទៅមុខទៀត ចៅកុំប្រព្រឹត្តការលាមកយ៉ាងនេះទៀតឡើយ" ៗ ឯអ្នកទោសក៏ក្រាបថ្វាយបង្គំព្រះហើយក្រាបលោកឃោមរាជ នឹងនាយភូឃុំហើយក៏រត់ចេញទៅនៅស្រុកក្រៅ លាក់ខ្លួនពុំឲ្យពួករាជការដឹងឮឡើយ ៗ



ឯឧកញ៉ាឃោមរាជក៏នាំនាយភូឃុំថ្វាយបង្គំលាព្រះពុទ្ធរូប ហើយវិលទៅកាន់លំនៅៗជាសុខសប្បាយកំចាយតែសព្ទប្រាប់គេថាអ្នកទោសនោះកាច់ច្រវាក់រត់ចាកគុកទៅបាត់ហើយ ៗ លុះនៅកន្លងកាលយូរមក រឿងនោះពុំស្លាត់បាត់ទៅឡើយជាហេតុឲ្យដឹងឮទៅដល់ឧកញ៉ាពលទេបៗ មានចិត្តត្រេកអរដោយសមតាមគំនិតដែលគិតរកឱកាសនឹងក្រាបទូលព្រះរាជាឲ្យដកងារឧកញ៉ាឃោមរាជនោះបង់ អាត្មានឹងបានទីនោះ ៗ មានកាលសម័យថ្ងៃមួយជាពេលាព្រឹក ព្រះរាជាស្ដេចចេញអង្គាសភត្ត គឺដាក់បាត្រលោកសង្ឃស្ដេចកំពុងទុកបាត្រ មានហ្វូងក្អែកទាំងឡាយហើរមកស្រែកកញ្ជ្រៀវកងរំពងទាំងផ្ទៃវាំងក្អែកពួកខ្លះហើរស្រែកយំ ទំតាមដើមឈើតាមដំបូលប្រាសាទដំណាក់ទីទៃ ៗ

ឯព្រះបរមចក្រី លុះស្ដេចទុកបាត្រសូរេចហើយទ្រង់ត្រាស់ថា អាសត្វក្អែកអស់នេះមានហេតុភេទអ្វីបានជាថ្ងៃនេះ វានាំគ្នាមកស្រែកគឹកងកោលាហលយ៉ាងនេះ ធ្វើម្ដេចនឹងបានដឹងភាសាវាអេះ ៗ

ឯឧកញ៉ាពលទេពអង្គុយគាល់នៅទីនោះ លុះបានឮព្រះបន្ទូល

ដូច្នោះបានឱកាសទើបក្រាបទូលឡើងថា "សូមទ្រង់ព្រះមេត្តា
ប្រោស មនុស្សយើងទាំងឡាយក្នុងព្រះនគរនេះពុំមាននរណា
មួយ អាចចេះភាសាសត្វឡើយឮថាអ្នកឧកញ៉ាយោមរាជគេ
ចេះភាសាសត្វ ដោយគេបានរៀនតអំពីអ្នកទោសដល់ទីប្រ
ហារម្នាក់ ហើយបានលែងអ្នលទោស ជាគ្រូគេនោះបង់សូម
ទ្រង់ព្រះមេត្តាប្រោស ឲ្យហៅមកសួរគង់ទ្រង់ជ្រាប"។ ព្រះរា
ជាបានទ្រង់ព្រះសណ្ដាប់ដូច្នោះក៏ប្រើរាជបំរើម្នាក់ ឲ្យទៅហៅ
ឧកញ៉ាយោមរាជចូលមកគាល់ ឯឧកញ៉ាយោមរាជ ឮថាទ្រង់
មានព្រះរាជឱង្ការឲ្យហៅទៅគាល់ដូច្នោះ ក៏នឹកពិកាលក្នុងចិត្តថា
ទ្រង់ឲ្យរកខ្លួនចូលទៅនេះ សូម្បីមានការប្លែកប្រាកដទើបសួរ
ទៅកាន់រាជបំរើនោះថា នាហ្មឺនណាគាល់នៅក្នុងទីនោះខ្លះរាជ
បំរើជំរាបថា លោកឧកញ៉ាពលទេពគាល់នៅទីនោះ ឧកញ៉ា
យោមរាជឮដូច្នោះ ក៏ដឹងខ្លួនថា អាពលទេពវាគង់ក្រាបទូល
ពោលទោសអញជាប្រាកដ គិតហើយឧកញ៉ាយោមរាជរៀប
អាត្មាម្ទីម្នាទៅជាមួយនឹងរាជបំរើនោះ លុះដល់ហើយក៏ចូលទៅ
ក្រាបបង្គំអង្គុយគាល់ក្នុងទីដ៏សមគួរ ឯព្រះរាជាទតយល់ឧកញ៉ា
យោមរាជចូលមកគាល់ហើយ ក៏ត្រាស់ថា "អើអ្នកយោមរាជ



ឥឡូវឧកញ៉ាពលទេពគេប្រាប់យើង ថាអ្នកឯងបានរៀន
ភាសាសត្វអំពីអ្នកទោសម្នាក់ បានលែងអ្នកទោសនោះចេញ
ចាកគុកទៅឥឡូវហ្វូងសត្វក្អែកទាំងឡាយវាមកស្រែក
កញ្ជ្រៀវកងរំពងជាកោលាហល យល់ជានឹងមានហេតុអ្វីមួយពុំ
ខាន បើដូច្នេះអ្នកឯងចេះភាសាសត្វចូរស្ដាប់វានិយាយគ្នាទៅ
មើល"។ ឧកញ៉ាយោមរាជក៏ទទួលព្រះឱង្ការទូលអនុលោមតាម
ថា ខ្លួនបានរៀនបានចេះដឹងភាសាសត្វពិតប្រាកដមែន លុះឮ
ព្រះឱង្ការប្រើឲ្យស្ដាប់សព្ទក្អែកដូច្នោះ ក៏ធ្វើជាបែរទៅស្ដាប់
សព្ទក្អែកម្ខាងទៀត លុះស្ងប់សព្ទក្អែកបន្តិច ក៏ក្រាបបង្គំទូលថា
សូមទ្រង់ព្រះមេត្តាប្រោស ហ្វូងក្អែកដែលទំលើដើមឈើនោះ
ជាហ្វូងក្អែកស្រុកក្រៅ ឯហ្វូងក្អែកដែលទំលើដំបូលមហាប្រាសា
ទនោះ ជាហ្វូងក្អែកនៅក្នុងក្រុងនេះ។ ព្រះរាជាឮដូច្នោះក៏
ត្រាស់សួរទៅវិញថា "ចុះក្អែកស្រុកក្រៅវាមកយំកងតើវាយំ
ថាដូចម្ដេច? ក្អែកក្នុងក្រុង តើកញ្ជ្រៀវថាដូចម្ដេច?។ អ្នក
ឧកញ៉ាយោមរាជក្រាបទូលថា "ក្អែកស្រុកក្រៅមានក្ដីក្ដៅក្រ
ហាយដោយអ្នកស្រុកក្រៅ ពុំបានធ្វើបុណ្យឲ្យទានដូចអំពីឆ្នាំ
មុនៗ គឺឆ្នាំមុនៗអាណាប្រជានុរាស្ត្រសំបូណ៌ស្រូវអង្ករគេនាំគ្នា

ធ្វើបុណ្យ និមន្តលោកសង្ឃឆាន់តាមភូមិលំនៅឯចំណីអាហារដែលសេសសល់នោះ គេបោះឲ្យទានក្អែកឬសត្វទៀតៗផងបណ្ដាលសត្វទាំងឡាយមានក្អែកជាដើម សឹងបានបរិភោគចំណីដែលសល់នោះទួទៅ សេចក្ដីសុខសប្បាយក៏មានគ្រប់តំបន់ឥឡូវឆ្នាំនេះ លោកឧកញ៉ាពលទេពជានាយក្សេត្របាត់មេកងអាជ្ញាលួងចេញទៅកត់ស្រូវ ធ្វើមិនត្រូវតាមប្រវេណីគឺយកពន្ធពីរាស្ត្រលើសប្រមាន ធ្វើមិនត្រូវតាមប្រវេណីគឺយកពន្ធពីរាស្ត្រលើសប្រមាណ រាស្ត្រគ្នាមានស្រូវតែត្រឹម ៤-៥ ថាំងក៏កត់គ្នាឲ្យជាប់ដែរឧកញ៉ាពលទេពឲ្យកត់ដល់ទៅស្រូវពូជ ស្រូវដំណើបស្រូវចំការប្រាំង យកជាពន្ធទាំងអស់ មួយទៀតស្រូវគ្នាមានត្រឹម៥០-៦០ កីទាយបង្កើនដាក់ជា ៩០-១០០ រាស្ត្រគ្នាឥតវ៉ាក៏មិនបានយកបុណ្យសក្ដិសង្កត់បង្គ្របគ្នាទៅតាមអំពើចិត្តផ្សេងៗ ពួកអាណាប្រជានុរាស្ត្រកើតក្ដីក្រលំបាកបានក្ដីក្ដៅក្រហាយតែរាល់ៗគ្នាបានជាឆ្នាំនេះមិនមាននរណា អាចធ្វើបុណ្យឲ្យទានដូចឆ្នាំមុនៗបាន ពួកក្អែកទាំងឡាយពុំបានទទួលទានបាយសម្លដែលសេសសល់អំពីការបុណ្យទាននោះឯង ទើបវានាំគ្នាចូលមកក្នុងក្រុង ដើម្បីថ្លែងសេចក្ដីលំបាករបស់រាស្ត្រដល់ពួកក្អែក បណ្ដា



ផាញ្ញាតិនៅក្នុងក្រុងឲ្យពួកក្អែកក្នុងក្រុងនាំសេចក្ដីក្ដៅក្រហាយឡើង ក្រាបបង្គំទូលព្រះករុណាជាម្ចាស់ផ្ទៃក្រោមឲ្យទ្រង់ជ្រាប ។ ការឧកញ៉ាពលទេពប្រព្រឹត្តខុសព្រះបញ្ញត្តិមានសភាពយ៉ាងនេះ សូមល្អងធូលីព្រះបាទស្ដេចទ្រង់ជ្រាប" ។

ឯព្រះបរមរាជា បានទ្រង់ព្រះសណ្ដាប់ពាក្យឧកញ៉ាយោមរាជដូច្នោះក៏ត្រូវព្រះទ័យ ទើបទ្រង់ខ្ញាល់នឹងឧកញ៉ាពលទេពកោតឆរាស្ត្រ ធ្វើឲ្យរាស្ត្រក្ដៅក្រហាយទាំងព្រះរាជអាណាខេត្តស្ដេចទ្រង់ឲ្យដកងារ ឧកញ៉ាពលទេពចេញចាកមន្ត្រី ប្រោសប្រទានឧកញ៉ាយោមរាជឡើងទីជា សម្ដេចចៅហ្វាទឡ្ហអគ្គមហាមសេនា ស្ដីរាជការចៅក្រសួងអធិបតី ។

**ចប់សេចក្ដីតែត្រឹមនេះ**

រឿងនិទាននេះ បានគិតដល់បុគ្គលទុច្ចរិតគិតប្រទូសរ៉ាយដល់បុគ្គលអ្នកឥតទោស បទលោកថា "បុគ្គលចងប្រទូសរ៉ាយដល់គេ ដែលពុំមានទោសអ្វីនឹងខ្លួនហើយ ទោសនោះត្រូវធ្លាក់មកលើខ្លួនឯងវិញ" ដូចយ៉ាងឧកញ៉ាពលទេព គិតប្រទូសរ៉ាយឧកញ៉ាយោមរាជនោះឯងឧកញ៉ាយោមរាជមានប្រាជ្ញាទទួលពាក្យខ្លួនបោទ គឺពលទេពក្រាបទូលថាយោមរាជចេះភាសាសត្វ

គេក៏ទទួលថាចេះដូចពាក្យខ្លួនថាដល់ស្តេចប្រើគេឲ្យស្តាប់សត្វ ភាសាក្អែក គេទទួលស្តាប់ ហើយគេថាក្អែកវានិយាយអំពីទោស ខ្លួនទៅកំហែងរាស្ត្រ បើខ្លួនប្រកែកថាមិនមែនវិញ នរណានឹង ទៅដឹងភាសាក្អែកជា២-៣ នាក់ផងនឹងយកជាសាក្សីថាមិនមែន នោះ ដ្បិតខ្លួនថាគេចេះហើយគេចេះតែម្នាក់ឯងនឹងមាននរណា ទៅចេះដឹងផង ៗ ឱកញ៉ាពលទេបទាល់ចំណេះខ្លួនឯង បានជា ពុំហ៊ានប្រកែកតវ៉ានឹងឱកញ៉ាយោមរាជក្នុងកាលនោះ មួយ ទៀតពាក្យឯណា ការឯណា ដែលខ្លួនបាននិយាយមុសាទៅហើយ តោងកុំគេចកុំវេវុះ ត្រូវប្រកាន់ការនោះឲ្យមាំដូចយ៉ាងឱកញ៉ា យោមរាជ នឹងបានវៀនចេះភាសាសត្វនោះកាលណា គឺខ្លួនចាញ់ កលអ្នកទោសនោះទេតែដល់ពលទេពក្រាបទូលថាចេះភាសា សត្វ គេក៏ទទួលថាចេះមែន ហើយគេនិយាយដាក់ទំលាក់ទោស មកលើខ្លួនឯងវិញ ខ្លួននឹងវេរីថាមិនមែនវិញឯណាក៏បាន ៗ អ្នកមានបញ្ញាត្រូវពិចារណាទៅទៀតចុះ ៗ

**ចប់តម្រាអនុលោមតាមហេតុទី ២៩។**



## រឿងឆ្មាស្រុក១ នឹងចាបពូក១

មានឆ្មាស្រុក១ ចាបពូក១ នាយគេចិញ្ចឹមនៅជាមួយគ្នាថ្ងៃ១ មានចាបព្រៃ១ ហើរមកទំនៅទីជិតនៃចាបពូកនោះ ហើយពោលពាក្យតិះដៀលចាបនៅក្នុងទ្រុងជាភាសាសកុណជាតិ ឯចាប នៅក្នុងទ្រុងក៏កើតទោសោទឡើង តាំងជេរប្រទេចទៅចាប ព្រៃវិញចាបទាំងពីរកើតជម្លោះជេរគ្នាទៅវិញទៅមកតែនឹង ប្រចឹកគ្នាពុំបាន ព្រោះ១នៅក្នុងទ្រុង១ នៅក្រៅទ្រុង ៗ ឯឆ្មាស្រុក បានឮចាបទាំងពីរឈ្លោះគ្នាដូច្នោះ ក៏ខឹងនឹងចាបព្រៃ ថា អាសត្វចង្រៃហេតុអ្វីវាមកឈ្លោះប្រកែកនឹងចាបជាសំឡាញ់ អញអេះ បើដូច្នេះអញនឹងជួយចាបជាសំឡាញ់ចុះ គិតហើយ ឆ្មានោះលបទៅចាប់ចាបព្រៃនោះបាន ហើយទំពាស៊ីសាច់ចាប ព្រៃកើតក្តីឆ្ងាញ់ពិសា ទើបថាអញមិនដឹងថាសាច់ចាបព្រៃមាន រសជាតិឆ្ងាញ់ដល់ម្ល៉េះសោះ បើដូច្នេះចាបដើមតាំងពីថ្ងៃនេះ ទៅអញនឹងស្វែងចាប់ចាបព្រៃអាស្រ័យជាចំណីខ្លួន ឆ្មានោះគិត ដូច្នោះហើយ ពីថ្ងៃនោះមកតាំងស្វែងលបចាប់ចាបព្រៃអាស្រ័យ ជានិរន្តរ៍ ថ្ងៃមួយឆ្មានោះរកចាប់ចាបព្រៃពុំបាន កើតញ៉ាម មាត់អត់ពុំបាន ទើបហែកទ្រុងចូលទៅចាប់ចាបជាសំឡាញ់

បរិភោគតាមក្តីប្រាថ្នាខ្លួនហោង ៗ

រឿងនេះ បានគតិដល់បុគ្គលជានាហ្មឺនធំឬចៅហ្វាយស្រុក ដែលពុំធ្លាប់លក់រាស្ត្រប្រជាម្តងសោះនោះអធ្យាស្រ័យក៏ល្មមសមគួរ តែបើបានលក់រាស្ត្របានប្រាក់មាសម្តងហើយ កើតញ៉ាមអត់ពុំបានដល់ក្រោយមិនយល់មុខនរណា ចេះតែលក់ទាំងអស់ទោះសាច់ញាតិសន្តានខ្លួនក្តី ក៏ចេះតែលក់មិនរើសមុខថានរណាឡើយ កើតដោយញ៉ាមបាន ដូចយ៉ាងឆ្មាស្រុកស៊ីចាបសំឡាញ់ខ្លួននោះឯង ៗ

**ចប់តម្រាគតិញ៉ាមមាត់អត់ពុំបានទី ៣០។**

## រឿងសត្វសំពោចចូលក្នុងជង្រុកស្រូវ

**និទាននេះមានដំណាលក្នុងក្បួនបារាំងសែស**

មានសត្វសំពោចមួយ ចូលទៅក្នុងជង្រុកស្រូវគេបាននៅស៊ីស្រូវដរាដល់សរីរៈធាត់ធំ ៗ

ថ្ងៃមួយអ្នកម្ចាស់ជង្រុក ដើរមកត្រង់ទីជង្រុកនោះដោយមានកិច្ចនឹងទៅស្រែ ឯសំពោចនៅក្នុងជង្រុកបានឮសព្ទសន្ធឹកជើងមនុស្សដើរមកដូច្នោះ ក៏ភិតភ័យតក់ស្លុត ស្ទុះរត់មកត្រង់បង្អួច ដើម្បីនឹងចេញតាមចន្លោះមេចន្ទ្រឹង តែចេញពុំរួចឡើយ ទើបពោលឡើងថា កាលអញចូលមក ក៏ចូលតាមចន្លោះមេ



ចម្រឹងនេះឯង មេចន្ទ្រឹកនេះសោត ក៏នៅជាប្រក្រតីចុះហេតុអ្វីបានជាចេញទៅពុំរួចដូច្នេះ ៗ គ្រាកាលនោះមានកណ្តុរមួយវាមកខាងមេចន្ទ្រឹង បានឮសំពោចនោះពោលពាក្យដូច្នេះក៏ឆ្លើយថាមេចន្ទ្រឹងនេះនៅដដែលដូចមុនទេ ប៉ុន្តែគ្រាកាលបងឯងចូលមកនោះគឺរូបបងស្គមតូចទើបចូលមកបាន លុះបងឯងមកនៅក្នុងជង្រុកនេះ បានបរិភោគស្រូវឆ្អែតស្កប់ស្កល់អត្តភាពបងឯង កើតធាត់ធំឡើងលើសមុន ហេតុនេះបានជាចេញទៅពុំរួច តែបងឯងកុំស៊ីស្រូវតទៅទៀត ស៊ូអត់ត្រាអត្តភាពស្គមតូច ដូចកាលមុននោះ ទើបបងឯងអាចចេញទៅរួចបាន ៗ សំពោចបានស្តាប់ពាក្យកណ្តុរ ថ្លែងដូច្នោះក៏ចូលចិត្តបានទើបតាំងអត់អាហារពីថ្ងៃនោះមក ទាល់តែស្គមតូចដូចមុនទើបចេញអំពីជង្រុកនោះទៅបាន ៗ

**ចប់សេចក្តីតែប៉ុណ្ណោះហោ។**

រឿងនេះ បានគិតដល់បុគ្គលអ្នកចូលធ្វើរាជការបានទទួលទានបៀវត្សប្រាក់ខែកើតមានសម្បត្តិបរិបូណ៌ ហើយចង់លែងធ្វើរាជការវិញ នោះមានតែលែងទទួលប្រាក់ខែបង់ ទើបអាចចេញចាកនាទីនៃរាជការទៅបាន មួយទៀត បុគ្គលចង់ចេញ

ទៅបួសជាភិក្ខុ សាមណេរសោត នោះមានតែលះសម្បត្តិទ្រព្យ ចោលបង់ ស៊ូអត់កុំបរិភោគបញ្ចកាមគុណនោះទើបចេញទៅ បួសជាភិក្ខុ សាមណេរបាន ។

បទអស់នេះ អ្នកប្រាជ្ញគប្បីពិចារណាទៅទៀតចុះ ។

**ចប់តម្រាគតិរើខ្លួនចេញចាកទុក្ខទី ៣១**

## រឿងឈ្មួញលក់លានឹងពួកចោរព្រៃ

**និទាននេះមានដំណាលក្នុងក្បួនបារាំងសែស**

មាននាយឈ្មួញម្នាក់មកអំពីប្រទេសក្រៅ នាំកូនឈ្មួញដឹក លាបរលា លីលាតាមផ្លូវលុះមកដល់ទីកណ្ដាលព្រៃស្ងាត់ មានពួក ចោរទាំងឡាយនៅចាំលួចចាំប្លន់មហាជនដែលដើរទៅមកក្នុង ផ្លូវនោះ ។ ថ្ងៃនោះ ពួកចោរបានឃើញនាយឈ្មួញមកដល់ទី នោះក៏នាំគ្នាចូលវាយប្លន់នាយឈ្មួញៗមានគ្នាតិច ស៊ូនឹងពួកចោរ នោះពុំបាន ទើបនាំគ្នាទៅកាន់ទិសានុទិសផ្សេងៗ ។ ឯពួកចោរ ក៏នាំគ្នាចោមចាប់លាជាពាហនៈលាឯណាដែលមិនមានទ្រព្យ របស់នៅលើខ្នង ពួកចោរពុំត្រូវការចាប់យកឡើយ គឺចាប់ តែលាដែលមានទ្រព្យរបស់ជាប់នៅលើខ្នង ។ កាលនោះពួក ចោរចាប់បានលាឈ្មោល១មានទ្រព្យលើខ្នង ហើយនាំគ្នាដឹក



ទាញទង់ទៅកាន់លំនៅវា លាឈ្មោលបានក្ដីទុក្ខវេទនាដោយ ចោរវាវាយ វាទាញទៅឥតក្ដីមេត្តាទើបមកគិតថា ពួកលាទាំង ឡាយបណ្ដាដែលមកជាមួយគ្នា គេសឹងផុតពីកណ្ដាប់ដៃពួកចោរ អស់នេះគឺវាពុំត្រូវការ នឹងចាប់នឹងចងយកព្រោះគេគ្មានរបស់ ទ្រព្យជាប់នៅលើខ្នង ដូចរូបអាត្មានេះ អាត្មាអញបានក្ដីទុក្ខ ទោសយ៉ាងនេះ ក៏ព្រោះរបស់ទ្រព្យជាប់នៅលើខ្នងនេះ ឯង គិតទៅទ្រព្យសម្បត្តិមាសប្រាក់កែវកងទាំងពួងនេះ ជាគ្រឿង នាំឲ្យកើតទុក្ខទោស គឺជាអាសិរពិស ចឹកអាត្មាឯងប្រាកដ ។ លាឈ្មោលនោះគិតឃើញក្ដីទុក្ខទោសអាត្មាដូច្នោះហើយ ក៏យំ សោកវិយោគ ដើរតាមពួកចោរនោះទៅ ដរាបដល់លំនៅ នៃចោរហោង ។

រឿងនេះ បានគតិដល់បុគ្គលអ្នកមានទ្រព្យសម្បត្តិមិនចេះ ប្រយ័ត្ន សម្បត្តិនោះជាពិសពោរពើតខ្លួនវិញ ដូចយ៉ាងនិទាន នាងនារីម្នាក់ ពាក់ខ្សែមាសទំហូពេជ្រ កង ចិញ្ចៀន ខ្សែដៃ តែងអាត្មាបង្អួតគេបង្អួរកាមតាមការលោកិយ ចុះដោយសារ កប៉ាល់មកពីស្រុកទន្លេធំ លុះមកដល់ក្រុងភ្នំពេញ នាងនោះក៏ ឡើងចាកនាវា យាត្រាកត្រង់ក្រោយវត្តឧណ្ណាលោមកាលនោះ

មានអាអ្នកលេងម្នាក់ឃើញនាងនារីដើរមកដល់ទីបានឱកាសហើយ ទើបវាក្លែងជាស្វាមីនៃនាងនោះ ស្ទុះទៅវាយធាក់ដោះយកខ្សែកងចារ៍ជេរស្ដីថា ខ្មោចមេចង្រៃអប្រិយ អញជាប្ដីវាមិនស្ដាប់ពាក្យអញឃាត់ខ្លះ គួរឬវាចចេសចេះតែទៅចោលឲ្យអញនៅចាំផ្ទះ រក្សាកូនពិបាកស្ទើរនឹងស្លាប់ បើដូច្នេះឲ្យគ្រឿងខ្សែមាសវាពាក់ធ្វើអ្វី ត្រូវអញអូសយកពីហងឯងវិញ កុំឲ្យជិនាវាពាក់ទៅឡើយជេរហើយ អានោះវារត់សំដៅកាន់ផ្លូវខាងជ្រុងគុកគេចខ្លួនបាត់ទៅហោង ។

ឯនាងនារីដួលចុះ ក្រោយក្រោកឡើងបានហៅគេឯងជួយចាប់ចោរប្លន់ ក៏ពុំមាននរណាមួយចូលជួយឡើយ ព្រោះគេឮពាក្យអាចោរជេរប្រទេចជាទំនងប្ដីប្រពន្ធ គេនឹកស្មានថាប្ដីគេប្រពន្ធគេ ជេរវាយគ្នាដូចធម្មតា បានជាគ្មាននរណាមួយជួយឡើយ ។ លុះអាចោររត់ទៅបាត់ហើយ ទើបនាងនោះប្រាប់គេថាមិនមែនប្ដីខ្លួនទេ ជាចោរវាយដណ្ដើមយកគ្រឿងមាសខ្លួនប្រាកដ ។ នាងនោះប្រាប់ឲ្យគេជួយដេញចោរនឹងចាប់វាក៏ចាប់វាពុំបានឡើយ ព្រោះវាទៅបាត់យូរហើយ នាងនារីក៏បានក្ដីទុក្ខទោសដូចគ្នានឹងរឿងលាដែលបានពណ៌នាមកនេះ ។



អ្នកប្រាជ្ញគប្បីដឹងដោយប្រការដូច្នេះ ។

**ចប់តម្រាគតិមានទ្រព្យជាប់ទោសមានប្រាក់មាសវិនាសរូបទី ៣២។**

## រឿងលានឹងឆ្កែមានចៅហ្វាយជាមួយគ្នា

**និទាននេះមានដំណាលក្នុងក្បួនបារាំងសែស**

មាននាយដំឡៅម្នាក់ផ្ទុកគ្រឿងស្បៀងអាហារក្នុងតាងដាក់លើខ្នងលា មានសុនខស្រុកមួយទៅជាមួយគ្នា លុះទៅដល់ទីវាលមួយមានដើមឈើដុះល្បោះៗ នាយដំឡៅនោះក៏ឈប់សម្រាកកំលាំងដោយពេលានោះជាពេលថ្ងៃត្រង់ ទើបចូលដេកសម្រាកក្រោមដើមឈើធំ លែងសត្វលាឲ្យស៊ីស្មៅប្រើឆ្កែឲ្យនៅឃ្លាលលា នឹងឲ្យមើលហេតុអន្តរាយឯទៀតៗផង ។

ឯសុនខកើតឃ្លានបាយក៏និយាយនឹងលានោះថា "ភឿនអើយគ្នាឃ្លានបាយណាស់ចូរឯងឱនខ្លួនចុះបន្ទាបខ្នងបន្តិច ឲ្យគ្នាយកបាយក្នុងតាងតោះអាស្រ័យ" ។ ឯលាឮឆ្កែសុំយកបាយដូច្នោះក៏មិនចង់ឲ្យដោយខ្លាចនាយផង ទើបតបថា "ពេលនេះមិនត្រូវចៅស៊ីទេ ចាំដល់ល្ងាចសិនសឹមយើងដាក់ឲ្យស៊ី" ។

សុនខក៏អង្វរថា "គ្នាឃ្លានណាស់ចាំល្ងាចពុំបានទេ ចូរភឿនដាក់មកឲ្យគ្នាស៊ីសិន" ។ លាក៏តបទៅវិញថា "ចាំនាយគាត់ភ្ញាក់

សិនចុះ សីមស៊ីទៀលានេះយើងមិនហ៊ានឲ្យទេ"ៗ សុនខនោះបាន ឮថាលាមិនព្រមឲ្យដូច្នោះក៏តូចចិត្តគិតខឹងនឹងលា តែពុំហ៊ានថា អ្វីទៅទៀតៗ ឯលានោះដើរកស៊ីស្មៅស៊ីស្លឹកឈើរៀងៗទៅ ដល់ជាយព្រៃធំ១ៗ

កាលនោះមានឆ្កែព្រៃមួយ បានឃើញលាមកស៊ីស្មៅតែឯង ក៏បោលមកនឹងខាំលាជាអាហារ លាឃើញឆ្កែព្រៃដេញមក ដូច្នោះ ក៏ភិតភ័យតក់ស្លុតរត់មកត្រង់ឆ្កែស្រុក ហើយហៅឆ្កែ ស្រុកថាសំឡាញ់អើយជួយគ្នាផងឆ្កែព្រៃវាដេញខាំគ្នាហើយៗ

ឯសុនខស្រុក ក៏ស្តីផ្ទាលទៅថា "អើលាអើយកាលអញសុំបាយ ស៊ីឯងថាចាំនាយគាត់ក្រោក ឥឡូវមានភ័យដល់មក អញចាំនាយ គាត់មកដែរ ទើបអញជួយបាន" ថាហើយសុនខក៏ធ្វើជាពុំនាំ ពាតាំងអង្គុយនៅមើលតែពីចម្ងាយហោងៗ ឯលាក៏ភិតភ័យក្រៃ ពេកណាស់ ឆ្កែព្រៃរឹតតែបោលខាំអំពីក្រោយត្របាក់កែងផុត ៗ លានោះក៏រឹងរឹតតែភ័យខ្លាំង តាំងបោលបោះផ្លោះទៅឯដើម ឈើធំ ដែលនាយដង្វាដេកនោះឯង ដល់ហើយក៏ស្រែកហៅ នាយឲ្យជួយអាត្មាឯនាយដង្វាបានឮសូរលាស្រែកដូច្នោះក៏ភ្ញាក់ ក្រោកឡើងម្នីម្នាបែរទៅឃើញឆ្កែព្រៃដេញខាំលា ក៏ស្រែក



ហៅសុនខស្រុកឲ្យជួយលាជាប្រញាប់ៗ

ឯសុនខស្រុក បានឮនាយហៅឲ្យជួយលាដូច្នោះក៏ស្ទុះម្នីម្នា បោលទៅដេញខាំឆ្កែព្រៃៗ ឃើញឆ្កែស្រុកក៏ខ្លាច ពុំអាច បោលដេញលាទៅទៀតឡើយ ស្ទុះរត់ចូលព្រៃបោលទៅ កាន់លំនៅអាត្មាវិញហោងៗ

ឯនាយដង្វា កាលឆ្កែព្រៃបោលបាត់ទៅវិញហើយ ទើប ហៅលានឹងឆ្កែស្រុកចូលមកសាកសួរហេតុនោះថា "លាឯងអញ ឲ្យទៅស៊ីស្មៅបានឲ្យឆ្កែទៅឃ្វាលជួយមើលក្តីអន្តរាយផង ឥឡូវឆ្កែព្រៃវាដេញខាំខ្លួន តើហេតុអ្វីខ្លួនក៏មិនទៅរកឆ្កែស្រុ កឲ្យគេជួយ ត្រឡប់ជាបោលមករកអញវិញ អញបានផ្តាំថា ឯងទៅរកស៊ីចុះ គ្នាសុំដេកសម្រាកកំលាំងបន្តិចល្មមដល់ពេល ត្រជាក់បន្តិច នឹងលើកបរទៅទៀត"ៗ

ឯលាក៏តបឡើងថា "កាលឆ្កែព្រៃវាដេញនោះខ្ញុំបាទបានរត់ ទៅរកឆ្កែស្រុក បានស្រែកហៅឲ្យជួយ ឆ្កែស្រុកគេពុំជួយឡើ យគេត្រឡប់ថាជានាយភ្ញាក់សិនទើបគេជួយ ឆ្កែស្រុកគេពុំនាំ ពាយ៉ាងនេះ បានជាខ្ញុំបានរត់មករកនាយឲ្យជួយ"ៗ នាយដង្វា ឮលាថាដូច្នោះក៏សួរទៅឆ្កែវិញថា "ម្តេចឯងមិនជួយលាអញ

បានផ្តាំផ្តាច់ថាឲ្យមើលក្តីអន្តរាយផង"។

ឆ្កែស្រុកឆ្លើយថាឲ្យការថា "កាលខ្ញុំបានឃ្លានបាយខ្ញុំបានសុំលាថា គ្នាឃ្លានបាយណាស់ចូរឯងបង្អោនខ្លួនចុះបន្តិច គ្នានឹងយកបាយកកអាស្រ័យនោះលាពុំឲ្យឡើយ គេថាចាំនាយភ្ញាក់សិនសឹមស៊ីចុះខ្ញុំបានខឹកខឹងនឹងលាយ៉ាងនេះ ដល់ឆ្កែព្រៃវាដេញលាមកលាស្រែកហៅឲ្យខ្ញុំបានជួយ ខ្ញុំបាទក៏តបពាក្យគេវិញថា ចាំនាយភ្ញាក់សិនសឹមជួយ ពាក្យខ្ញុំបាទថានោះគឺថាតែតាមពាក្យលាដែលពោលមុននោះឯងសូមនាយជំរះក្តីនេះ ឲ្យឃើញខុសត្រូវដោយយុត្តិធម៌ចុះ"។ នាយដង្ហោសួរទៅលាវិញថា "អើលាហេតុអ្វីឆ្កែគ្នាសុំបាយកកស៊ី ម៉េចចៅមិនឲ្យវាស៊ីទៅហះ"។

លាតបទៅវិញថា "បានជាខ្ញុំមិនទាន់ឲ្យនោះព្រោះខុសកាលពេលា គឺពេលព្រឹកលោកនាយនឹងឆ្កែនេះ បានបរិភោគរួចហើយពេលថ្ងៃត្រង់លោកនាយមិនដែលពីសា។ តែដល់ពេលល្ងាចតែម្តងវាក៏ស៊ីត្រូវពេលនឹងនាយដែរ កាលឆ្កែវាសុំបាយស៊ីនោះគឺជាពេលថ្ងៃត្រង់ ឆ្កែឃ្លានឥតរបបខុសពេលនាយពីសាហេតុនោះខ្ញុំឲ្យធ្វើម្តេចបានៗជាខ្ញុំបាទថាចាំនាយលោកភ្ញាក់សិនសឹមឲ្យស៊ី បានជាខ្ញុំបានថាដូច្នេះ ព្រោះបាយត្រីអស់នេះជា



របស់ផងនាយ ។ អនុញ្ញាតឲ្យទើបខ្ញុំបាទហ៊ានដាក់ឲ្យ នឹងចាត់ចែងឯងឲ្យដោយចិត្តឯងឯណាក៏បាន វិស័យអ្នកនៅនឹងនាយចៅហ្វាយឬនៅនឹងសំណាក់គ្រូចារ្យ លោកឲ្យឯងទទួលទុកដាក់ស្បៀងអាហារ ឬទ្រព្យសម្បត្តិឯណានីមួយ ត្រូវតែរក្សាថែទាំងរបស់អស់នោះ កុំឲ្យវិនាសទៅដោយការមិនគួរបង់មែន បើនាយចៅហ្វាយឬគ្រូអាចារ្យលោកបង្គាប់ថាឲ្យនរណាៗនោះទើបអាចនាំចេញឲ្យទៅអ្នកនោះៗ បានមួយទៀតអ្នករក្សាទ្រព្យសម្បត្តិនាយចៅហ្វាយនេះត្រូវឲ្យដឹងវត្ថុនោះៗផងគឺវត្ថុណា ចំណីណាទុកយូរទៅពុំបាន ល្មមប្រាប់នាយឬរកនាយនឹងប្រាប់ពុំឃើញក្តី ក៏គប្បីយកមកចែកបាយឲ្យភឿនផងអាស្រ័យទៅក៏គួរ ព្រោះវត្ថុចំណីនោះ ទុកទៅនឹងខូចអសារឥតការចោលបង្សៀតខ្ញុំបាទកាន់ច្បាប់យ៉ាងនេះ បានជាសុនខសុំបាយស៊ីខ្ញុំបានមិនហ៊ានឲ្យ"។

ឯនាយដង្ហោបានឮពាក្យលាពោលត្រូវច្បាប់ដូច្នោះក៏ត្រេអរទើបនិយាយទៅនឹងឆ្កែវិញថា "អើបាសុនខ លានិយាយឲ្យការនេះត្រូវច្បាប់ល្អហើយចៅឯង តើសុខចិត្តចាញ់ប្រៀបលាហើយឬៗ ពុំសុខចិត្តយ៉ាងណាចូរថាទៀតចុះ"។ ឯសុនខក៏តបថា

"ខ្ញុំបាទពុំសុខចិត្តចាញ់លានេះទេ ព្រោះលាវាថាលោកនាយនឹង
ខ្ញុំបាទបរិភោគអាហារមានពេលា គឺបរិភោគតែព្រឹកនឹងល្ងាច
ឯពេលថ្ងៃត្រង់ថ្ងៃរសៀលបរិភោគពុំបាន ចុះត្រង់រូបលានេះ
ម៉េចក៏ស៊ីស្មៅ ស៊ីស្លឹកឈើតែវាលល្ងាច ព្រឹកក៏ស៊ី ថ្ងៃក៏ស៊ី ស៊ីគ្មាន
ឈប់សោះ ត្រង់យើងម្ដេចក៏ចាំបាច់មានពេលមានពេលានេះបទ
១ មួយទៀតពាក្យលាថា អ្នករក្សាទ្រព្យរបស់នាយចៅហ្វាយ
ត្រូវដឹងវត្ថុដែលទុកយូរបាននឹងទុកយូរមិនបាន វត្ថុណាទុកយូរ
មិនបាននឹងខូចចោលនោះត្រូវអ្នករក្សាប្រាប់នាយ ឬបើរក
នាយនឹងប្រាប់មិនឃើញទេ ត្រូវនាំចេញមកឲ្យពួកភឿនអា
ស្រ័យសិនក៏គួរ អើដូចយ៉ាងបាយកកនេះ ជាវត្ថុសំណល់សល់អំពី
ព្រឹក ទុកយូរទៅពុំបាននឹងផ្អូមខូចចោលបង់អើខ្ញុំបាទសុំបាយ
កកនេះអាស្រ័យ ហេតុម្ដេចលាមិនឲ្យខ្ញុំបាទៗ នឹងបានសុំវត្ថុ
ដែលដែលទុកយូរបានឬចំណីថ្មោងកាលណាសូមលោកនាយពិចា
រណាត្រង់បងនេះឲ្យទាន តាមពាក្យដែលលាដោះស្រាយមក
នោះមើល?។

ឯលាបានឮឆ្កែកសំនួរស្របតាមពាក្យខ្លួនដូច្នោះក៏ឆ្លើយ
កាត់ឡើងថា "នែចៅសុនខ ឯពាក្យយើងថាខ្លួនលោកនាយនឹង



តួចៅឯងបរិភោគមានពេលមានវេលា ត្រង់យើងជាសត្វលាស៊ី
ស្មៅ ស៊ីស្លឹកឈើមិនមានពេលនេះ ព្រោះអាហារចំណីខុសគ្នាខាង
ចៅឯងបរិភោគបាយត្រី សាច់ ជាអាហារៗនេះតែបរិភោគ
ឆ្អែតហើយ មិនបាច់ឈប់ទើមកទំពាអៀងលំអិតទៀតឡើយ
ឯងខាងយើងជាពួក គោ ក្របី បរិភោគស្មៅជាអាហារៗនេះ
តែបរិភោគឆ្អែតហើយ ត្រូវឈប់ទើចេញមកទំអៀងទាលតែ
ល្អិត កាលល្អិតហើយ អាហារនោះតិចចុះមិនពេញពោះទៅវិញ
ហេតុនោះ ទើបយើងពួក គោ ក្របី បរិភោគពុំមានពេលឈប់
យូរដល់ល្ងាចបាន មួយទៀត តិណជាតិទាំងឡាយ សឹងដុះដាស់
ពាសទួទៅទាំងធរណី បណ្ដាលសត្វព្រៃក្ដី សត្វស្រុកក្ដី ត្រូវការ
អាស្រ័យ មិនចាំទិញដូរឬសុំនរណាទេ ត្រូវស៊ីបានឥតថ្លៃ ក៏ឯ
អាហារបាយ ត្រី សាច់ ចំណែកខាងមនុស្សឬសត្វដែលត្រូវស៊ី
នោះ សឹងបានមកដោយទិញដូរគេទើបបានមក នឹងទៅបរិ
ភោគឥតវេលាដូចយ៉ាងស្មៅនោះពុំបាន ជាការចុះទុនច្រើនៗ
នាំឲ្យបានក្ដីក្រលំបាកទៅខាងមុខ មួយទៀត ទោះសត្វស៊ីស្មៅ
ក្ដី ស៊ីបាយក្ដី តែមានម្ចាស់ចាត់ឲ្យស៊ីយ៉ាងណា ក៏តោងប្រព្រឹត្តតាម
ការរបស់ម្ចាស់នោះឯង មួយទៀត ឆ្កែពោលពាក្យថាបាយកក

ជាបាយសំណល់ជាវត្ថុទុកយូរពុំបានក៏ពិតមែន តែទុកទៅត្រឹម ពេលល្ងាច ក៏មិនទាន់ផ្អូមខូចដែរ នៅអាស្រ័យទៀតបាន ហេតុ នោះបានជាយើងមិនឲ្យ យើងចាំជំរាបនាយសិនជាគាត់ឲ្យឬមិន ឲ្យក៏តាមចិត្តលោកនាយចុះ"។

ឯនាយដង្ខៅឮសត្វទាំងពីរដដែកគ្នាទៅវិញទៅមកដូច្នោះ ក៏ឆ្លើយកាត់ឡើងថា "ការអស់នេះជាទោសខុសធ្លាក់មកលើ អញជានាយវិញចុះ ព្រោះអញមិនបានមើលកល មើលការ ផ្ដាក់ផ្ទុកផ្ដាំលាឲ្យបែងបាយថ្ងៃ ចែកឲ្យឆ្កែគ្នាស៊ីផង អំពីថ្ងៃ នេះទៅលាឯងមើលពេលគួរឲ្យឆ្កែគ្នាបានអាស្រ័យផងចុះ"។ ថាហើយនាយដង្ខៅក៏រៀបប្រដាប់លើកដាក់លើតាងលាបរលា ទៅកាន់ស្រុកនៃអាត្មាហោង។

រឿងនេះ បានគតិដល់បុគ្គលអ្នកនៅនឹងនាយចៅហ្វាយឬ គ្រូអាចារ្យ ដែលលោកឲ្យខ្លួនរក្សាទ្រព្យសម្បត្តិ គួរយកគតិ លាជាច្បាប់នៃអាត្មា ទើបបានក្ដីគាប់ក្នុងលោកិយនេះហោង។

**ចប់តម្រាគតិអ្នករក្សាទ្រព្យនាយទី ៣៣។**



# រឿងជើងដៃប្រច័ណ្ឌនឹងមាត់

## និទាននេះមានដំណាលក្នុងក្បួនបារាំងសែស

មានកាលថ្ងៃ១ ពួកអវយវៈទាំងឡាយគឺដៃពីរ ជើងពីរ មាត់ មួយនាំគ្នានិយាយថា "យើងសព្វថ្ងៃនេះលំបាកនឹងប្រកបការរក ស៊ីណាស់"។ ជើងទាំងពីរឆ្លើយថា "ខ្ញុំឯងនេះព្រឹកឡើងកាលណា រវល់តែនឹងដើរទៅឯនោះខ្លះឯនេះខ្លះមិនចេះឈប់ឈរឡើយ ដៃទាំងពីរឆ្លើយឡើងថា "ខ្ញុំឯងក៏រវល់មិនមានឱកាសឈប់សោះ ទៀវតែដេកលក់ទើបបានឈប់ តែភ្ញាក់ឡើងកាលណារវល់តែ ចាប់នេះចាប់នោះ មិនចេះអស់ដោយហោចទៅតែត្រឹមស៊ី បាយស៊ីចំណីអ្វីៗ ដៃក៏រវល់បាប់ចំណីបញ្ចុកមាត់ដែរ"។ មាត់ ឆ្លើយឡើងថា "ខ្ញុំឯងក៏រវល់មិនឈប់ដូចគ្នា តែភ្ញាក់ឡើងកាល ណាចរចានិយាយថានេះ ថានោះទៅផ្សេងៗដោយហោចទៅ តែត្រឹមបរិភោគអ្វីៗ មាត់ក៏រវល់ទំពា រវល់លេបអាហារបញ្ចូ លទៅ ការភ្ញាក់ងារខ្ញុំឯងមានសភាពយ៉ាងនេះ"។ ជើងដៃបានឮ ដូច្នោះ ក៏សួរទៅមាត់ថា "អាហារនោះតើធ្លាក់ទៅនៅលើរូប ណា?។ មាត់ប្រាប់ថា "អាហារអស់នោះតែស៊ីហើយ ក៏ធ្លាក់ទៅ នៅលើក្រពះទាំងអស់"។ "អើសព្វអាហារដែលពួកយើងបាន

មកដោយជើង ដោយចាប់កាន់ ដោយទំពាលេបចូលទៅ គឺទៅនៅលើក្រពះទាំងអស់ អាក្រពះនោះតើវាមកជួយធ្វើការអ្វីខ្លះដែរ ឬវានៅស្ងៀមព្រងើយកន្តើយទេ? មាត់ប្រាប់ថា "អាក្រពះនោះវានៅស្ងៀមទទេទទេវានឹងបានជួយកិច្ចការអ្វីក៏ឥតអង្គីមាន"ៗ

ទើបជើងឆ្លើយឡើងថា "អញរវល់ជើងទៅរកស៊ីបានអាហារៗ នោះក៏គួរធ្លាក់មកលើអញអេះ នេះម្តេចឡើយក៏បានទៅលើអាក្រពះ ដែលវានៅស្ងៀមនោះវិញ បើដូច្នេះពីថ្ងៃនេះទៅ អញលែងដើររកស៊ីទៀតហើយ"ៗ ឯដៃក៏ពោលថា "អញខំធ្វើការសព្វសរពើសព្វថ្ងៃនេះ អាហារសោតក៏ធ្លាក់បានទៅលើអាក្រពះនោះវិញ បើដូច្នេះពីថ្ងៃនេះទៅ អញលែងចាប់ពាល់កាន់ធ្វើអ្វីៗហើយ ទុកឲ្យអាក្រពះវាចេញមកធ្វើការដាំស្លដាក់ពោះវាចុះ"ៗ ឯមាត់ក៏ពោលឡើងថា "អញសោតខំនិយាយជេរពោលប្រទេច ខំស៊ី ខំទំពា ខំលេប ឯអាហារក៏ពុំតាំងនៅលើខ្លួនអញ វាត្រឡប់បានៅអាក្រពះនោះវិញ អាក្រពះវាគ្មានជួយធ្វើការអ្វីសោះ អើពីថ្ងៃនេះទៅអញលែងនិយាយលែងពោល លែងទំពាស៊ីអ្វីៗហើយ ទុកឲ្យអាក្រពះវា



ក្រៀមស្វិតពោះវាចុះទើបសមមុខវា ដែលវាកំជិលធ្វើការនេះ"ៗ

ឯអវយវៈទាំង៣និយាយត្រូវគំនិតគ្នាហើយទើបចូលដេកលើគ្រែលែងប្រកបជាភ្នាក់ងារខ្លួនទីទៃៗ ពីថ្ងៃនោះហោងៗ ឯក្រពះនោះកាលអវយវៈក្រៅមិនបញ្ចូលអាហារទៅឲ្យដូច្នោះហើយ ក៏កើតស្ងួតក្រៀម ភ្លើងតេជោធាតុពុំមានអាហារនឹងដុតផ្សាយទៅសព្វសកលកាយបាន សកលកាយនោះកាលបើពុំមានរសអាហារនឹងផ្សាយហើយ វាយោធាតុក៏មានកំលាំងអាចផាត់អាបោធាតុ ឲ្យរីងស្ងួតស្វិតទៅខ្លះកាលបើធាតុប្រែប្រួលពុំប្រក្រតីហើយ ឯអវយវៈទាំងឡាយក៏ស្វិតស្គមរីងទៅ វាតសមុដ្ឋានាពាធក៏បៀត បៀតធ្វើឲ្យចុកសៀតទៅផ្សេងៗៗ

ឯដៃជើងមាត់ទាំង៣ ពួកកាលណាបើកើតវិបត្តិដល់ខ្លួនទីទៃៗហើយ ពុំអាចនឹងតាំងនៅជាប្រក្រតីបាន ទើបមកប្រជុំគ្នាវិញទៀតថា ពួកយើងតាំងតែពីលើកលែងប្រកបការ មិនបញ្ចូលអាហារទៅឲ្យអាក្រពះនោះ ឥឡូវនេះវាស្វិតស្ងួតពុំបានផ្សាយរសជាតិអាហារដល់ពួកយើងឡើយ ពួកយើងបានក្តីស្គាំងស្គមទ្រមទ្រុឌគ្មានកំលាំងសោះ មិនតែប៉ុណ្ណោះដាលកើតជា

រោគចុកសៀត រួយអស់សាច់សរសៃថែមទៀត អើបើពួកយើងបង្អត់អាហារ អាក្រពះយ៉ាងនេះហើយគង់នឹងអន្តរធានវិនាសទៅទាំងអស់គ្នាមិនខានព្រោះក្រពះគ្មានអាហារជាកំលាំងនឹងផ្សាយរសជាតិដល់ពួកយើងនេះឯង បើដូច្នេះពួកយើងត្រូវប្រកបការតាមភ្នាក់ងាររៀងខ្លួនដូចកាលមុនវិញ ពួកអវ័យវៈពិគ្រោះឃើញក្ដីទុក្ខទោសព្រមគ្នាដូច្នោះហើយ ជើងក៏ក្រោកដើរទៅប្រកបការតាមដើម ដៃសោតក៏ចាប់ពាលធ្វើការងារតាមដើម មាត់សោតក៏ហានិយាយស្ដី ហាស៊ីបានអាហារដាក់ដូចមុនហើយ កើតមានកំលាំងផ្សព្វផ្សាយរសជាតិនោះទៅសព្វសព៌ាង្គកាយ ដៃជើងមាត់ក៏បានក្ដីសុខសប្បាយឡើងដូចប្រក្រតីតាមកាលមុននោះវិញហោង ៗ

រឿងនេះ បានគតិដល់បណ្ដាអាណាប្រជាជនទាំងឡាយក្នុងប្រទេសរាជបុរី ទុកជាអវ័យវៈគឺដៃជើងមាត់ ឯក្រពះនោះទុកជាមហាក្សត្រធិបតី មែនបើអាណាប្រជាជនទាំងឡាយមិនថ្វាយសួយសារអាករប្រាក់ពន្ធដារថ្លៃរាជការហើយ មហាក្សត្រាធិបតីនឹងដល់នូវក្ដីក្រីក្រ ពុំមានប្រាក់សម្រាប់ប្រកបការរក្សាព្រះនគរ នឹងចិញ្ចឹមក្រុមការតាមក្រសួងទាំងឡាយមាន



ក្រុមយោធាទាហានជាដើម កាលបើស្ដេចគ្មានក្រុមមន្ត្រីសេនាបតីគ្រប់ក្រសួង ហើយនឹងផ្សាយអំណាចរក្សាអាណាប្រជាជនក្នុងប្រទេសខ្លួនទៅម្ដេចបាន ពួកចោរ ពួករាជបច្ចាមិត្រដឹងថាព្រះនគរពុំមានអំណាចហើយ វានឹងនាំគ្នាលើកមកបុកបែនប្លន់ញាំញីចាប់មហាក្សត្រិយ៍ នឹងពួកអាណាប្រជានុរាស្ដ្រយកជាឈ្លើយជាខ្ញុំគេអស់ទៅ បាននូវក្ដីទុក្ខវេទនាព្រាត់ប្រាសចាកភូមិចាកលំនៅទៅផ្សេងៗដូចគ្នានឹងក្រពះដែលពុំមានអាហារតាំងនៅ នឹងផ្សាយរសជាតិទៅដល់អវ័យវៈតូចធំពុំបាននោះឯងពិតមែនមហាក្សត្រាធិរាជពុំបានរកស៊ីជួយធ្វើការរាស្ដ្រ នៅតែក្នុងវាំងក្នុងដំណាក់ដូចគ្នា នឹងក្រពះពុំបានជួយធ្វើការពួកអវ័យវៈនោះឯង ៗ អ្នកមានបញ្ញាគួរពិចារណាមើលចុះ មហាក្សត្រាធិរាជនោះ ត្រូវតែអវ័យវៈខាងក្រៅគឺអាណាប្រជានុរាស្ដ្រថ្វាយសួយសារអាករបង់ប្រាក់ថ្លៃពន្ធបំរុងឲ្យមហាក្សត្រិយ៍ លោកនឹងបានចំណាយចែកចាយ សាងព្រះនគរឲ្យមាំមួន ខ្លួនរាស្ដ្រនឹងបានក្ដីសុខឥតទុក្ខភ័យ ដែលកើតអំពីពួកពាលវាកំហែងនោះហោង គួរបង់ប្រាក់ជូនរាជការហើយពួកយើងជារាស្ដ្រទាសក្នុងព្រះនគរ កុំពោលថាមហាក្សត្រិយ៍នៅទំនេរឡើយ ៗ

**ចប់តម្រាគតិរាស្ត្របង់ប្រាក់ពន្ធទី ៣៤ (ចប់ ភាគទី ៦ តែប៉ុណ្ណោះ)។**